លោក ឱត សាម៉ុន ស៊ីញ៉ូដៃទៅរកចិត្រា ជាសញ្ញាថាគេត្រូវដើរតួនាទីជាអ្នកសម្ភាសន៍ក្នុងពេលនេះជំនួសលោក។ បុរសស័ក្តិបួនរីករាយរំភើបចំពោះឱកាសនេះ តែនាយក៏ប្រុងប្រយ័ត្នខ្លាប់ខ្លួនដែរ។

គាត់សង្ឃឹមថាបរិយាកាសនេះអាចនាំបុរសកន្ធាត់ឲ្យនិយាយចេញនូវការពិតទាំងប៉ុន្មានដែលលាក់បាំងក្រោមចរិតលក្ខណៈក្រឡេចក្រឡុចរបស់គេ។

«ខ្ញុំព្រមទទួលស្គាល់ថា បើប៉ូលិសសួរយោបល់ខ្ញុំរឿងការបាត់ខ្លួនស្រីៗ អ្នកដែលខ្ញុំគិតដល់មុនគេគឺ អាម្នាក់មកពីអាមេរិកនោះ!»

គ្រប់គ្នានៅស្ងៀម  ឯមហាវីនដកដង្ហើមហាក់ភ័យព្រួយណាស់ តែគេនៅតែតាំងចិត្តនិយាយបន្ថែម៖

«Lorenzo ខ្ញុំសង្ស័យគេនោះបំផុត!»

មហាវីននិយាយ ហើយក៏ធ្វើមុខស្រពោន។

នៅចំពោះមុខ ចិត្រាដឹងថាថៅកែម្នាក់នេះមិនមានភាពស្មោះត្រង់គ្រប់គ្រាន់នៅក្នុងការផ្តល់ចម្លើយទេ។ តែទោះបីចម្លើយអ្វីក៏ដោយ ប៉ូលិសរមែងតែងរកឃើញចំណុច«ឆ្លោយ»មួយដែលមានប្រយោជន៍។ ឱកាសមាន គេព្រមនិយាយកាន់តែច្រើន ប៉ូលិសកាន់តែអាចកំណត់បាននូវជំហរពិតរបស់សាក្សី ឈានទៅដល់ការពិចារណាវាយតម្លៃស្ថានការណ៍ខ្លះឬទាំងស្រុង។

គេឆ្លោយមាត់នូវសំណួរខ្លីៗបន្ទាន់តាមសន្ទុះចិត្តចង់ដឹង៖

«លោកស្គាល់គេដោយវិធីណា?»

មហាវីនធ្វើមុខស្លុងមើលឆ្ងាយសន្លឹម តាមបង្អួចកញ្ចក់ ទៅបរិវេណខាងក្រៅបន្ទប់។

នៅទីនោះប៉ូលិសពីរនាក់កំពុងឈរជជែកគ្នា។ នេះជាបន្ទប់ដែលមានការយាមកាម២៤ម៉ោងលើម្ភៃបួនម៉ោង។ គេនិយាយដូចកំពុងតែរំឭកការចងចាំឡើងមកវិញហើយឈប់ខ្លាចអ្វីទាំងអស់។

«ពេលខ្ញុំរៀបសមោសរពណ៌ព្រះចន្ទនេះដំបូង ខ្ញុំហៅ Rose មកពីឡុងដុង! នាងថ្លៃខ្លាំងណាស់តែសមោសរខ្ញុំជាជំនួញសុទ្ធសាធ! ខ្ញុំគិតរឿងចំណូលជាធំដូចគ្នា! មិនទាន់ចាប់ផ្តើម

ផង ខ្ញុំបានទទួលការកក់ទុកពីមនុស្សម្នាក់! គេមកពីអាមេរិកមានឈ្មោះក្នុងលិខិតឆ្លងដែនថា ជំនិត វីរៈ ចំណែកឈ្មោះLorenzo គេទើបតែប្រើនៅពេលដើរតួជាតារាសប្បុរសដ៏ល្បីជាមួយលុយច្រើនមិនដឹងប្រភព!»

លោកឱត សាម៉ុននៅមមីភ្នែកស្ដាប់ពាក្យចម្លើយមិនហ៊ានឲ្យបាត់មួយម៉ាត់ណាទាំងអស់ ចំណែកដៃចិត្រាវិញក៏កត់ត្រាឡើងលឿនស្លេវតាមសន្ទុះចិត្តចង់ដឹងរបស់នាយ។ ដៃសរសេរមាត់ក៏សួរកាត់៖

«ខ្ញុំចង់ដឹងលម្អិតពីកម្មវិធីរបស់លោក! ហេតុអ្វីសមោសរនោះកំណត់យកតែកូនស្រីអ្នកមាន ហើយគ្មានទីតាំងប្រាប់មុន គ្មានកម្មវិធីគ្រោងទុក?»

មហាវីនហាក់បីដូចជាមានមោទនភាពឡើងវិញក្នុងការនិយាយរំឭកអំពី កម្មវិធីដ៏អស្ចារ្យរបស់ខ្លួន។ថ្ពាល់គេចាប់ផ្ដើមក្រហមព្រោះគេកំពុងទទួលអារម្មណ៍ថា រំភើបចំពោះអ្វីមួយដែលខ្លួនបានធ្វើ ប៉ុន្តែពេលនេះ ក្លាយទៅជាអតីតកាល ដោយសាររឿងគួរឲ្យសោកស្ដាយមិនដឹងក្បាលកន្ទុយអស់ទាំងនេះ។

ជាមួយនឹងកំហឹងចិត្ត គេនិយាយពន្យល់មកកាន់អ្នកកត់ត្រា៖

«វាគឺជាកម្មវិធីដ៏អស្ចារ្យមួយដែលទេពធីតានិងជួបទេវបុត្រ ព្រោះយើងមិនមែនទទួលតែស្រីស្អាតទេ ប៉ុន្តែទេវបុត្តមកក្នុងតួនាទីជា Sponsor សុភាពនារីមកជាភ្ញៀវ!»

«មុខរបរដឹកញីបន្ស៊ីឈ្មោល?»

ចិត្រាងើបមុខសួរទាំងមិនសូវពេញចិត្ត។ ប៉ុន្តែមហាវីនហាក់មិនញញើតគេនៅតែការពារខ្លួនដោយហេតុផលមិនចេះរីងស្ងួត៖

«លោកថាយ៉ាងណាក៏បាន ប៉ុន្តែកុំឲ្យភ្ញៀវខ្ញុំឮ ព្រោះថាពួកគេពុំមែនសត្វ ពុំមែនញី ក៏ពុំមែនឈ្មោល!»

ចិត្រានៅស្ងៀមធ្វើមុខស្មើ ទុកឲ្យបុរសនេះបន្តលេងល្ខោនសម្ដែងទៅមុខទៀត។ ឃើញដូច្នេះ មហាវីនក៏និយាយបន្ថែមដោយមោទនភាព៖

«ពួកគេមកពីសង្គមជាន់ខ្ពស់ ការស្វែងរកមនុស្សឋានៈដូចគ្នាមករួមកម្មវិធីជារឿងត្រឹមត្រូវណាស់ អត់មានអីទាស់ខុសទាំងអស់! នេះរបៀបស្វែងរកឱកាសឲ្យពួកគេបានជួបជាមួយមនុស្សថ្មីៗ គ្រាន់តែគេត្រូវការកំណត់អត្តសញ្ញាណបន្តិច! បើ Sponsor កាន់តែឡូយ អ្នកចូលរួមកាន់តែត្រូវរើសសម្រិតសម្រាំង!»

«ចង់បានន័យថា ខាងប្រុសជាអ្នកបង់លុយឲ្យក្រុមហ៊ុនលោកឯង ហើយគេមានសិទ្ធិសម្រេចថាឲ្យនារីម្នាក់ណាមកចូលរួម? ការសម្រេចចិត្តស្ថិតនៅលើគេ?»

មហាវីនងក់ក្បាល ជាសញ្ញាមិនបដិសេធ។

ចិត្រាដៀងសម្លឹងមេកោយបន្តិច មុនពេលងាកមកវិញមើលមហាវីនពិនិត្យពិច័យធ្វើឲ្យបុរសធាត់មើលមកនាយវិញមិនញឹន។ ចិត្រាធ្វើមុខស្មើដាក់សំណួរដោយទម្លាក់សំឡេងទាបៗ៖

«កម្មវិធីរបស់លោកឯង មានបញ្ចូលទាំងការរួមភេទដែរអត់?»

លោកឱត សាម៉ុនងាកមុខចេញ ចំណែកមហាវីនផ្ទុះសំណើច។

«សើចធ្វើស្អី?»

«សើចព្រោះថាចិត្តពួកមនុស្សប្រុសយើង ឲ្យតែផ្តោតឡើង គឺសួររឿងអស់ហ្នឹង!»

ចិត្រាខឹងឆ្អួលចុងច្រមុះ។

គេមិនអាចកំណត់បានទេថាជននេះកំពុងតែចំអកឡកឡឺយឲ្យខ្លួន ឬកំពុងតែព្យាយាមពង្វាងដាន។ គេនៅតែផ្ទង់អារម្មណ៍ជាមួយបទសម្ភាសន៍។

«លោកឯងធ្វើកម្មវិធីអ៊ីចឹងសោះ តែមានលុយជួលពិធីការលំដាប់មកពីឡុងដុង! ស្រីម្នាក់ហ្នឹងមិនត្រឹមចាយលុយដូចក្រដាស ហើយនៅរស់នៅក្នុងបទដ្ឋានដូចសេដ្ឋីទៀត តើចំណូលកម្មវិធីសមោសរឆ្កួតយក៏ហ្នឹងរកបានមួយយប់ប៉ុន្មានអ្ហះ? ហើយហេតុអី Sponsor អស់ហ្នឹងវាឡប់យកលុយទៅចោល បើមិនបានស្អីមកវិញនោះ? »

«ឯងមិនទៅសួរ Lorenzo?»

មហាវីនគំហកមកវិញ ធ្វើឲ្យចិត្រាគាំង។

រីឯលោកសាម៉ុនគោះពូកផាំង ទាញអារម្មណ៍សេដ្ឋីកន្ទាត់ឲ្យឈប់ព្រហើនដាក់ចិត្រា។

«ពិនិត្យអាកប្បកិរិយារបស់លោកឡើងវិញមហាវីន!»

«កូនចៅលោកមិនចេះធ្វើការទេ ខ្ញុំសុំដូរប៉ូលិស!»

ដៃគេរាវរកទូរសព្ទ តែគេដឹងខ្លួនវិញថារបស់អស់នោះត្រូវដកហូតអស់តាំងពីគេចូលមកដល់ទីនេះ ដូច្នេះរឹទ្ធិអំណាចរបស់គេលែងអាចកំណាចបានមុនទៀតហើយ។

មហាវីនធ្វើមុខក្រញូវ ចំណែកលោក ឧត្តមសេនីយ៍ឲ្យសញ្ញាទៅចិត្រាសួរបន្ត។ វរសេនីយ៍ត្រីក៏បោះសំណួរបន្ថែមមិនបង្អង់ មិនខ្វល់ថាអ្នកដែលត្រូវឆ្លើយកំពុងគិតយ៉ាងណា?

«ហេតុអីឲ្យខ្ញុំទៅសួរ Lorenzo?»

មហាវីនទប់ចិត្តឆេវឆាវ ឆ្លើយដោយមិនងាកមុខមកវិញ៖

«ព្រោះពេលគេមកដល់ស្រុកខ្មែរកាលណា គេបានទិញសិទ្ធិជា Sponsor ធំតែម្នាក់ឯង!»

ចិត្រាងាកមកសម្លឹងលោកឧត្តមសេនីយ៍។ សំណួរសម្ងាត់ដែលនាយចង់សួរគឺថា តើបុរសអាណិកជនម្នាក់នោះជាមនុស្សប្រុសតែម្នាក់គត់ដែលទិញផ្តាច់ឱកាសជួបស្រីៗអភិជនទាំងអស់នោះមែនដូចមហាវីនអះអាងដែរឬអ្វី? លោកឱត សាម៉ុនក្រោកដើរយឺតៗមកក្បែរមហាវីន។

គាត់ចាប់ផ្តើមសួរម្តង៖

«តាំងពីចាប់ផ្តើមមក លោករៀបចំបានប៉ុន្មានដងហើយ? មិនមែនឲ្យខ្ញុំទៅសួរ Lorenzo ដែរទេ មែនអត់?»

មហាវីនមិនអាចគេចវេះមិនឆ្លើយនោះទ។ គេនិយាយខ្លី៖

«ទើបតែ៦ដងទេ!»

«ភ្ញៀវប៉ុន្មាននាក់?»

ចិត្រាដកដង្ហើមវែងសម្លឹងមុខមហាវីន។ បុរសនេះនៅអេះអុញទីទើរ មុនពេលសម្រេចចិត្តឆ្លើយ៖

«៣០នាក់! តែ... ក្នុងកុងត្រាខ្ញុំបានសន្យាមិនបង្ហាញសមាសភាពពួកគេទេ!»

គាត់ងើបមុខសម្លឹងគូកន ធ្វើឲ្យចិត្រាខំកត់ត្រាទុកយ៉ាងញាប់ ឯបុរសចំណាស់ប្រញាប់សួរឈ្លេចបន្ថែម៖

«Lorenzo បានជួបជាមួយស្រីៗទាំងអស់?»

មហាវីនធ្វើមុខធុញថប់ក្នុងការឆ្លើយ។ គេញីសក់មុនពេលផ្តល់ចម្លើយ៖

«គេបង្ហាញខ្លួននៅកន្លែងនោះ ពួកគេញ៉ាំអាហារ រាំរែក តែការណាត់ជួបតទល់ពីរនាក់ធ្វើឡើងផ្សេងទៅតាមការសម្រេចចិត្តរបស់ភាគីទាំងសងខាង! ហើយខាងក្រុមហ៊ុន មិនបានដឹងឮទេ! យើងគ្រាន់តែផ្តល់ឱកាសឲ្យពួកគេជួបគ្នានៅទីនេះតែប៉ុណ្ណោះ!»

«Lorenzo មិនអនុញ្ញាតឲ្យមានបុរសផ្សេងចូលរួមកម្មវិធីទេ?»

ចិត្រាភ្លាត់មាត់សួរ។ មហាវីននៅស្ងៀម មិនឆ្លើយ។ លោកឱត សាម៉ុនចាប់ផ្តើមឈ្លេចបន្ថែម៖

«វាមិនសមថាសមោសរមួយទាំងមូល មានភ្ញៀវប្រុសតែម្នាក់! លោកគ្មានភស្តុតាង គ្មានសាក្សី បើនិយាយរឿងនេះចេញទៅ តើមានគេជឿប៉ុន្មានភាគរយ?»

មហាវីនព្រិចភ្នែកគិត។ ទីបំផុតគេនិយាយសារភាព៖

«ដំបូងខ្ញុំមិនព្រមទេ ប៉ុន្តែ Rose ជាអ្នកបញ្ចុះបញ្ចូល! យើងបានចំណូលហើយមាន Sponsor ធំ ខ្ញុំគ្មានហេតុផលអ្វីត្រូវជំទាស់ទេ! ចុងក្រោយខ្ញុំដឹងរឿងបាត់ខ្លួនភ្ញៀវស្រីៗទាំង៤នាក់ ខ្ញុំគិតស្មុគ ដេកមិនលក់បក់មិនល្ហើយ ហើយក៏ហៅ Rose មកសួរនាំ! ចុងក្រោយ ខ្ញុំគិតថា Lorenzo ចូលមក Sponsorកម្មវិធីនេះ គឺវាចង់ដណ្តើមយកសមោសរពណ៌ព្រះព្រះចន្ទទៅរកស៊ី ដោយចូលមករៀនសូត្រមុនប៉ុណ្ណោះ! ហើយរឿងថ្មីមួយទៀតដែលខ្ញុំទើបនឹងស៊ើបដឹង គឺភាពជិតស្និទ្ធរវាង Rose និងអាម្នាក់នោះ អ៊ីចឹងហើយខ្ញុំសង្ស័យពួកគេហ្នឹងរួមគ្នាលេងខ្ញុំ!»

ប៉ូលិសទាំងពីរនៅស្ងៀមពិចារណា គ្រប់យ៉ាងដែលត្រូវបានលាតត្រដាងចេញពីមាត់ម្ចាស់កម្មវិធី។

«មិននឹកស្មានថា Rose ទទួលវាសនាចុងក្រោយរបៀបនេះសោះ!»

«លោកគិតថា អ្នកណាធ្វើអីនាង?»

ចិត្រាចាក់សួរ។

ភាគទី២៥

មហាវីនមិនរង់ចាំយូរទេ ដូចបានឱកាសដើម្បីចូលសាច់រឿងអ៊ីចឹង គេចាប់ផ្ដើមបង្ហាញអាការៈបន្ទោសថាឲ្យការងាររបស់ប៉ូលិស៖

«លោកនៅចាំស្អីទៀត? ម៉េចមិនទៅសួរចម្លើយអាម្នាក់នោះ?»

«Lorenzo?»

មហាវីនមិនឆ្លើយ តែប៉ូលិសអាចមើលឃើញកំហឹងនិងភាពមិនសុខចិត្តនៅក្នុងកែវភ្នែកបុរសធាត់។ លោកឱិត សាម៉ុនក្រពាត់ដៃនិយាយ៖

«លោកធ្លាប់មានទំនាស់អីផ្សេងជាមួយម្នាក់នោះដែរអត់?»

«គ្មានទេ!»

គេងើបមុខមកប្រកែកភ្លាម។

លោកឱិត សាម៉ុនងក់ក្បាល៖

«សម្រាកចុះ! អរគុណសម្រាប់កិច្ចសហការ!»

គាត់បម្រុងចាកចេញ ស្រាប់តែគេសម្លឹងចិត្រាហើយសម្លឹងគាត់សួរភ្លែត៖

«ខ្ញុំចេញបានពេលណា?»

ឧត្តមសេនីយ៍ងាកមកសម្លឹងសេរ៉ូមលើដៃគេ។ គាត់សួរមួយៗវិញ៖

«លោកចង់ទៅណា របួសមិនទាន់ជា! ពិធីការលោកបាត់មិនទាន់រកឃើញ!»

មហាវីនឆ្លើយខែងរ៉ែង៖

«ស្តង់ដារពេទ្យនេះ ខ្ញុំមិនចូលចិត្ត! ខ្ញុំចង់ដូរទៅថៃ!»

«លោកគិតថា នៅបរទេសលោកមានសុវត្ថិភាពជាងស្រុកខ្មែរ?»

មហាវីនទីទើរ គិតចុះឡើង។ ការមានសុវត្ថិភាព ឬមិនមាន គេខ្លួនឯងផ្ទាល់ជាអ្នកដឹង។ គេហាក់ពិចារណាពេលឮពាក្យអស់ទាំងនេះ ប៉ុន្តែបន្ទាប់មកមួយខណៈ មាត់គេនៅតែចចេស៖

«ខ្ញុំសុំកម្លាំងប៉ូលិសថែម តែខ្ញុំសុំចេញទៅសម្រាកកន្លែង VIP នេះ!»

លោកឱិត សាម៉ុនពិចារណា...

គេបន្ថែមភ្លាមទាំងរវើក្មេកចុះឡើង៖

«ហើយអស់លុយប៉ុន្មានក៏ដោយ មនុស្សឬសព ខ្ញុំចង់បានដំណឹងពីបុគ្គលិកខ្ញុំ Rose!»

ចិត្រាដកដង្ហើមវែង មុនពេលនិយាយ៖

«ទាក់ទងនឹង Rose ខ្ញុំសូមលោកជួយរឿងមួយទៀតមហាវីន!»

គេឆ្លើយដោយមិនងើបមុខ៖

«និយាយមកចុះ!»

«ខ្ញុំចង់បានទំនាក់ទំនងក្រុមគ្រួសារគេនៅឡុងដុង!»

គេនៅស្ងៀមទីរទើរ....

«កុំប្រាប់ថាលោកមិនដែលសូម្បីតែដឹងប្រវត្តិពិតរបស់នាង?»

ចិត្រាថាឱ្យគេតិចៗតែមហាវីនហាក់ម៉ូម៉ៅ។គេងើយមុខមើលនាយសក្តិបួនឱីវិញ។

ឧត្តមសេនីយ៍ឱិត សាម៉ុនបោះសម្តីសម្រាលបរិយាកាស៖

«ចង់ដឹងពីអ្នកណាម្នាក់ត្រូវទៅមើលនៅផ្ទះរបស់គេ ដោះស្រាយក្តីណាមួយប៉ូលិសត្រូវដឹងឬសគល់នៃបញ្ហា! ករណី Roseយើងមិនទៅឡុងដុងទេ តែយើងចង់ស្តាប់សម្តីក្រុមគ្រួសារគេបើចាំបាច់ ខ្ញុំចង់និយាយវីដេអូខលជាមួយអ្នកផ្ទះរបស់គេ!»

មហាវីនៅស្ងៀមហើយបង្ខំចិត្តងក់ក្បាលផ្ញក់ៗ....

«សម្រាកចុះ! ចាំលោកគ្រាន់បើបន្តិចចាំខ្ញុំមកទៀត!»

គាត់ក្រោកឡើង ជូនពេលមហាវីនស្រែកឃាត់៖

«ហើយ ទូរសព្ទមិនឱ្យកាន់ អ្នកបម្រើម្នាក់មិនឱ្យមកក្បែរខ្ញុំទៅរកប្រវត្តិ Rose ពីណាមក?»

ឱិត សាម៉ុនសម្លឹងប្រតិកម្មជននេះមុនពេលឆ្លើយធ្វើហី៖

«ដល់ពេល ខ្ញុំគង់តែអនុញ្ញាត!»

គាត់ចាកចេញទាំងញញឹមឌឺមួយ។

មហាវីនខាំមាត់ក្តៅក្រហាយ....នៅពីក្រោយខ្នងឧត្តមសេនីយ៍ ចិត្រានិយាយស្រាលៗផ្តាំ៖

«ខ្ញុំដឹងថាលោកនៅមានរឿងច្រើនទៀតដែលមិនទាន់សម្រេចចិត្តនិយាយប្រាប់ប៉ូលិស!»

វគ្គ អំបោះជំពាក់មុខ

នៅតាមរបៀងមន្ទីរពេទ្យលោកឱិត សាម៉ុនកៀកស្មានាយសក្តិបួន៖

«លោកយល់ថាមហាវីនមានរឿងអីទៀតនៅលាក់យើង!»

ចិត្រាគ្រវីក្បាលហើយឆ្លើយផងគិតផង៖

«ខ្ញុំអត់ច្បាស់ទេ! តែភ្នែកគេបញ្ជាក់ថាគេមិនត្រង់!»

«យើងមិនចាំបាច់ត្រូវការអ្នកណាត្រង់ទេក្នុងការសួរចម្លើយ! សំខាន់តើយើងអាចសួររបៀបណាឱ្យគេចាំបាច់ត្រូវនិយាយការពិតណាផ្តល់ផលល្អដល់សំណុំរឿង!»

គាត់ទម្លាក់ដៃចោលស្មាចិត្រា ព្រោះស្នងការ Roy រត់មកសំដៅប៉ូលិសទាំងពីរ។

«ខ្ញុំស្មានថាមកយឺតហើយ!»

គេនិយាយទាំងញញឹមដាក់អនាគតលោកប៉ាក្មេក តែកន្ទុយភ្នែកបង្ហាញអារម្មណ៍សម្ងាត់ដែលមិនពេញចិត្តវត្តមាននាយស័ក្តិបួនឡើយ។

«ខ្ញុំចាំលោក!»

ឧត្តមសេនីយ៍ ឱិត សាម៉ុន និយាយទាំងកៀកស្មា Roy ដើរសំដៅឡានរបស់គេដែលចតចង្ក្រាង។

«ឡាននេះទំនើបពេកហើយ សម្រាប់ទៅសួរចម្លើយគេ?»

គាត់និយាយលេងបញ្ចិតបញ្ចៀងនឹងការលេងខ្លួនរបស់អនាគតកូនប្រសា ដែលខ្លួនគាត់មិនប្រាកដថាបុរសនេះនឹងអាចនាំវាសនាកូនស្រីទៅរកសុភមង្គលពិតប្រាកដនៅឡើយ។

Roy ប្រញាប់បញ្ចេញហេតុផល៖

«តារាសប្បុរសនោះជាអ្នកមានកប់ពពក! យើងទៅក្នុងសភាពពិបាកភ្នែកពេក ក៏គេមិនឲ្យតម្លៃ! មកពីខ្ញុំគិតអ៊ីចឹង!»

ឱត សាម៉ុន សើចតិចៗ។ គាត់ដៀងភ្នែកសម្លឹងចិត្រាដែលមិនហ៊ានលូកមាត់ក ហើយគាត់សម្លឹងទៅរថយន្តទំនើបដែលម្ចាស់វាកំពុងចុចបើក។ រថយន្តតម្លៃសែនដុល្លាររបស់ស្នងការចរិតស្មារ ធ្វើឲ្យឱត សាម៉ុននឹកឃើញរឿងផ្សេង៖

«មានដំណឹងពីឯកមាន?»

«អត់សោះ!»

ស្នងការ Roy និយាយតបទាំងជ្រប់មុខ។ ចំណែកចិត្រាតឹងទ្រូងសាជាថ្មី។ ពេលនេះស្ថិតក្នុងបេសកកម្ម គេមិនអាចបង្ហាញមនោសញ្ចេតនា ប៉ុន្តែគ្រប់យ៉ាងកាន់តែបញ្ចេញមកថា អ្នកដែលកំពុងលេងល្បែងជាមួយប៉ូលិសពិតជាមិនមែនធម្មតា។

«ប៉ូលិសដែលទៅតាមបាត់ទាំងអស់ដែរ?»

Roy ងក់ក្បាល។

លោកឱត សាម៉ុនសម្លឹងទៅសក្តិលើស្មានាយ។ គាត់ដឹងថា បុរសក្មេងកំពុងតឹងតែង ហើយស្និទ្ធស្នាលចង់បានជំនួយពីខ្លួនតែប៉ុណ្ណោះ។

ពួកឧក្រិដ្ឋលេងសាហាវដល់ថ្នាក់នេះ មិនដល់ប៉ុន្មានម៉ោងទៀតទេ ថ្នាក់លើប្រាកដជាសួរនាំ ហើយសក្តិលើស្មានាយ Roy នេះមិនដឹងថាអាចជ្រុះដែរ ឬក៏អត់?

គាត់លួងលោម៖

«មិនអីទេ! យើងនៅមានពេល ដរាបណាគ្រួសារខាងផានូមិនទាន់ដាក់ពាក្យបន្តឹងថា កូនស្រីបាត់ខ្លួន រឿងមិនទាន់វិវត្តអាក្រក់ពេកដល់ត្រចៀកថ្នាក់លើទេ!»

គាត់គោះស្មាគេ ធ្វើឲ្យបុរសក្មេងលួចរលីងរលោង៖

«ខ្ញុំគ្មានបានការទេ! បើត្រូវគេដកសក្ដិក៏តាមហ្នឹងចុះ!»

គេនេះមិនសមទំនងថាជាមនុស្សភ្នែកទន់ដល់ថ្នាក់នេះសោះ បើតាមចិត្រាលួចគិត។ ទោះយ៉ាងណាគេនៅតែតាមលបមើលថា តើលោកឧត្ដមសេនីយ៍នឹងជួយបុរសនេះដោយមធ្យោបាយណា?

គាត់មិនមាត់ ហើយឱនឡើងលើឡានខាងក្រោយដែលគេបើកទ្វារជូន។ ហាក់ក្រឡេកទៅឃើញអ្វីមួយ គាត់សួរពីលើឡានទាំងទ្វារមិនទាន់បិទ៖

«កុម្ម៉ង់ការនោះ...?»

«បាទកូនចៅខ្ញុំ!»

Roy ឆ្លើយតបសុភាពរាបសារ តែត្រូវគាត់រាដៃ៖

«មិនបាច់ឲ្យទៅទេ! យើងមិនមែនទៅចាប់មនុស្សឯណា!»

គេទីទើរគាត់ក៏ពន្យល់៖

«ទៅតែបីនាក់យើងបានហើយ! ក្មេងមកពីអាមេរិកនោះ យើងមិនទាន់មានអ្វីមាំសម្រាប់ប្ដឹងគេទេ! ចំណែកលើកគ្នា ទៅច្រើននាំតែមនុស្សផ្អើល!»

គាត់ងាកទៅបញ្ជាចិត្រា៖

«លោកឡើងមកបើកឡានទៅវរសេនីយ៍ត្រី!»

Roy សម្លឹងមកចិត្រាទាំងមិនជឿថា គេក៏អាចទៅជាមួយបាន។

លោកឧត្តមសេនីយ៍បក់ដៃហៅឲ្យស្នងការមកអង្គុយក្បែរ។ គេឡើងមកយឺតៗ ទាំងមិនពេញចិត្តព្រោះនៅបាំងខាងមុខនាំរថយន្តដ៏ទំនើប ចិត្រាកំពុងឡើងមកអង្គុយកន្លែងចង្កូត។

មនុស្សនេះគ្មានអីពិសេសស្រោប់ហើយក្នុងកែវភ្នែកស្នងការ គ្រាន់តែគេមិននិយាយ ប៉ុន្តែគេមិនដែលសម្ដែងថាខ្លួនពេញចិត្តនាយស័ក្តិប្អូនម្ដងឡើយ។

គាប់ជួន ការងាររំដោះស្រីស្អាតកាលពីម្សិលត្រូវបាននាយកាត់មុខយ៉ាងឡូយឆាយទៀត អារម្មណ៍ច្រណែនរឿងអីថាមិនធំ។

«ពូមានរឿងមួយទៀតចង់ប្រាប់!»

«បាទ!»

គេដកអារម្មណ៍មកស្តាប់អនាគតឪពុកក្មេក។ បុរសចំណាស់ញញឹមដកឯកសារមួយស្តើងចេញពីក្នុងអាវធំ។

«ចិត្រាបានការអនុញ្ញាតជាផ្លូវការហើយក្នុងការចូលរួមស៊ើបក្តីបាត់ខ្លួននេះជាមួយផ្នែកព្រហ្មទណ្ឌ!»

គាត់បោះក្រដាសទៅមុខឲ្យនាយស័ក្តិបួន។ ចិត្រាគួរតែដឹងដោយមិនបាច់ប្រាប់ថា ហេតុអ្វីបានជាឧត្តមសេនីយ៍ព្រហ្មទណ្ឌម្នាក់នេះ មិនព្រមប្រគល់ឯកសារឲ្យកាលនៅខាងក្នុង បែរជារង់ចាំទាល់តែនៅតទល់ជាមួយស្នងការទើបប្រាប់គេពីការអនុញ្ញាតផ្លូវការនេះ?

ថ្លើមគេរីកសឹងថាដុះស្លាបអាចហោះទៅលើមេឃបាន។

គេចេញឡានទាំងញញឹមភ្លេច អស់ទុក្ខព្រួយ ប៉ុន្តែគេក៏គួរតែដឹងដែរ ថាតើចិត្តលោកស្នងការនៅខាងក្រោយខ្នងនេះកំពុងសៅហ្មងកម្រិតណា។

រថយន្តលូននាំប៉ូលិសទាំងបីមកលើមហាវិថីរលោងស្រិល។

លោកឱត សាម៉ុនសួរទៅបុរសដែលកំពុងបើកបរខាងមុខ៖

«លោកស្គាល់កន្លែងគេចិត្រា?»

«បាទ?»

គេឆ្លើយខ្លីតែគាត់ញញឹមពេញចិត្ត។

ផ្ទះតារាសប្បុរសពុំមែនងាយរកជួបទេ ព្រោះគេមានផ្ទះច្រើន ហើយមានល្បិចច្រើន។ លើកលែងតែពេលនេះ ចិត្រាបានធ្វើការជាមួយបណ្តាញប៉ូលិស ពុំនោះគេក៏មិនអាចដឹងថាទៅរកពេលណាជួបងាយៗដែរ។

វគ្គ ចម្លើយ Lorenzo

វឌ្ឍនៈត្រហេបត្រហាបជាងសព្វមួយដង ក្នុងការចូលមករកអ្នកប្រុសតូចពេលនេះ។ គេរត់តក់ក្រហល់ឡើងមកដល់បន្ទប់បាយ ធ្វើឱ្យ Lorenzo ដែលកំពុងកាន់សមស្លាបព្រាត្រូវជូតមាត់ចោលអាហារ។

គេមិនទាន់សួរយ៉ាងណាគ្រាន់តែងាកសម្លឹងមើលមកមនុស្សជំនិត បង្កប់នូវចម្ងល់ក្នុងកែវភ្នែក។ វឌ្ឍនៈខ្សឹបតឿន៖

«អ្នកប្រុសតូចមើលទូរទស្សន៍បន្តិចឬនៅ!»

Lorenzoចងចិញ្ចើមក្នុងពេលដែលវឌ្ឍនៈលូកដៃចុចតេឡេបញ្ជាបើក។

«មនុស្សស្រីម្នាក់ដែលប្រភពជឿថាជាពីធីការល្បីត្រូវបាត់ខ្លួនពីផ្ទះ បន្សល់នូវរថយន្តទំនើបផ្ដុងចោលក្រោមស្ពាន ក្រុងតាខ្មៅ!»

ការរាយការណ៍ព័ត៌មានក្នុងបណ្ដាញinternetដែលវឌ្ឍនៈទើបនឹងបើកបង្ហាញនេះ ដូចទឹកមួយផ្តិលជះមកចំកណ្ដាលមុខបុរសអាណិកជន។

សំឡេងម៉ាត់ៗនោះរាយការណ៍បន្ថែម៖

«អ្នកនាងRose ត្រូវបានគេដឹងថាជាអាណិកជនខ្មែររស់នៅប្រទេសអង់គ្លេស! នាងមានឈ្មោះក្នុងលិខិតឆ្លងដែនថាវិធីតា ហើយត្រូវបានគេសង្ស័យថាក៏ជា ម្ចាស់កម្មវិធីសមោសរចម្លែកមួយដែលល្បីក្នុងពេលចុងក្រោយនេះ ថាពាក់ព័ន្ធនឹងការបាត់ខ្លួនរបស់នារីៗក្នុងសង្គមអភិជន! អ្នកនាង Rose ត្រូវបានគេរាយការណ៍មកថា មានទម្លាប់រស់នៅតែម្នាក់ឯង ដូច្នេះប៉ូលិសមិនទាន់អាចធ្វើការសន្និដ្ឋានបានថា ពេលនេះនាងមានគ្រោះថ្នាក់ឬមួយបាត់ខ្លួនទៅណានៅឡើយ»

Lorenzo ងើបចាកចេញពីបន្ទប់បាយ ឆ្ពោះទៅទទួលភ្ញៀវ ដែលសូរសព្ទពីទូរទស្សន៍កំពុងលាន់មកក្រអៅ។ ទឹកមុខគេគ្មានអ្វីបង្ហាញថារីករាយនោះទេ។ ដៃគេលូកចុចទូរស័ព្ទញាប់ស្មេរ ចំណែកនៅពីក្រោយខ្នងគេ ជំនួយការវឌ្ឍនៈដើរត្រុនៗតាមមកពីក្រោយទាំងទឹកមុខពេញដោយទុក្ខព្រួយ។

«ខ្ញុំចុចរាប់ភ្លេចហើយ ទាក់ទងមិនចូល!»

«អ៊ីចឹងសោះបានជាយប់មិញ ប៉ូលិសអស់នោះទៅដល់ផ្ទះRose ?»

វឌ្ឍនៈចូលមកកាន់តែកៀកហើយគេវាចាដោយបារម្ភ៖

«លោកប្រុសទូរសព្ទមកពីអាមេរិកពីរដងហើយ!»

គេនិយាយតិចៗ ពេល Lorenzo ឡើងជណ្ដើរកុបៗឆ្ពោះទៅរកបន្ទប់ធ្វើការ។

តារាសប្បុរសនិយាយទាំងមិនចង់ហើបមាត់៖

«បងឯងគ្រាន់តែលេសដោះសាឲ្យខ្ញុំក៏មិនចេះនិយាយដែរ?»

គេរុញទ្វារចូលបន្ទប់ធ្វើការ Lorenzo ក្នុងអាកប្បកិរិយាមិនសប្បាយចិត្ត។

«បងវឌ្ឍនៈ ប៉ូលិសសុំចូលជួបមេ!»

សំឡេងអ្នកយាមទ្វាររត់មកប្រាប់ លាន់រំពងដល់ជាន់ខាងលើហាក់ដូចជាបន្ទាន់ណាស់ ធ្វើឲ្យ Lorenzoចងចិញ្ចើមសៅហ្មង។

វឌ្ឍនៈយល់ចិត្តចៅហ្វាយក្មេង។ Lorenzo ត្រូវប៉ូលិសទាន់នៅផ្ទះអ្នកបាត់ខ្លួន ត្រូវហៅមេធាវីមកនាំចេញមកផ្ទះទាំងយប់ ពេលនេះមិនទាន់ដឹងដំណឹងពី Rose ហើយ នៅមិននៅត្រូវប៉ូលិសបង្ហាញខ្លួនរុកកួនដល់ផ្ទះ ពេលថ្មើរណេះមិនឲ្យចិត្តមួហ្មងម្ដេចកើត?

«ប្រាប់គេទៅ ចៅហ្វាយសម្រាន្តហើយ!»

វឌ្ឍនៈបញ្ជាតិចៗទៅតាមចរិតសុភាពរបស់គេ ប៉ុន្តែសំឡេងលោកឱត សាម៉ុន លាន់មកតបឮខ្ទរផ្ទះ ហាក់មិនសុភាពដូចនាយឡើយ៖

«តែខ្ញុំថាមេរបស់លោកគេងមិនលក់ទេ!» (ជាសម្ដីរបស់Roy ឬឱត សាម៉ុន?)

ឧត្ដមសេនីយ៍ Roy ស្ទងការវ៉ៃក្មេងឫកពាឡូយឆាយហំហាន និយាយពីខាងក្រោមមកក្នុងឫកពាបែបចំអកឡុកឡឺយ។

ពេលដែលលោកឧត្តមសេនីយ៍ ហើយជាតិ ចិត្រាមនុស្សជំនិតកំពុងរង់ចាំជាន់ខាងក្រោម ស្នងការបែរជាឈានឡើងជណ្តើរទឹបៗ ដោយមិនបានអញ្ជើញនឹងមិនបានក្រែងចិត្តធ្វើឲ្យ Lorenzo ងាកមកសម្លឹងទាំងមុខស្មើស្លេកព្រោះខឹង។

«ខ្ញុំអាចប្តឹងពួកលោកដែលមករុករានទន្ទ្រានលំនៅឋានរបស់ខ្ញុំ!»

Lorenzo និយាយទាំងក្តៅចិត្ត តែសំឡេងគេស្រាលៗ។ ដៃគេបោះទូរសព្ទចោលទៅលើសាឡុង ធ្វើឲ្យគ្រប់គ្នាជឿថាគេកំពុងតែមិនសប្បាយចិត្តដល់កម្រិតពិតមែន។

«សូមមេត្តាយោគយល់! ខ្ញុំមានរឿងសំខាន់ៗនិងបន្ទាន់ត្រូវសួរនាំលោក!»

ឧត្តមសេនីយ៍និយាយស្លូតបូត កាត់ផ្តាច់បរិយាកាសអ័ព្ទអួ ធ្វើឲ្យនាយRoyដឹងថាខ្លួនកំពុងតែ

ជ្រុលបញ្ចេញសារជាតិនៅនឹងមុខអនាគតឪពុកក្មេកទៅហើយ នឹងឱនរើសមកលាក់ទុកវិញក៏មិនកើត មានតែថយទៅម្ខាងជៀសផ្លូវ ហើយជ្រប់មុខនៅស្ងៀមលែងពោលប៉ប្លូច។

ការជាប់ដាននៅផ្ទះ Rose កាលពីយប់ មិនទាន់ធ្វើឲ្យគ្រប់យ៉ាងប្រក្រតីវិញផង ពេលនេះប៉ូលិសលើកគ្នាមកដល់ផ្ទះទាំងក្រុមមិនឲ្យ Lorenzo តឹងតែង?

«អញ្ជើញអង្គុយ!»

វឌ្ឍនៈអារកាត់ជំនួសមេទៅតាមចរិតដឹងខុសត្រូវវែងឆ្ងាយរបស់គេ។

Lorenzo ទប់ចិត្តដកដង្ហើមយូរ មុនពេលអង្គុយចុះយឺតៗដែរ។

ស្នងការ Roy ចោលភ្នែកមករកអាណិកជន ហើយនៅត្រេងត្រាងយឺតៗមុនពេលដាច់ចិត្តអង្គុយចុះមកក្រោយគេ។

«ជំនិត វីរៈ! លោកដឹងហើយខ្ញុំកាន់សំណុំរឿងនារីៗបាត់ខ្លួន!»

ក្នុងពេលដែលចិត្រាទទួលអារម្មណ៍ថាឈ្មោះ«ជំនិត វីរៈ»ម្នាក់នេះ ដូចជាធ្លាប់បានឮនៅឯណាម្តង តែរកនឹកមិនឃើញ។ ឧត្តមសេនីយ៍ ឱត សាម៉ុននិយាយមកក្រអួនៗ មិនមានទីទើរះ

«តាមចម្លើយសារភាពរបស់មហាវីន នារីៗកូនអ្នកមានទាំងបួននាក់មុនពេលបាត់ខ្លួនសុទ្ធតែមានណាត់ជួបតទល់ជាមួយលោក! ពួកគេយកសមោសរពណ៌ព្រះចន្ទជាលេសប៉ុណ្ណោះ ស្រីៗមកកម្មវិធីនេះគ្មានអ្វីក្រៅតែពីចង់ជួបលោក!»

ប្រសិនបើគេគិតថាខ្លួនកំពុងតែមានអ្នកដទៃណាម្នាក់លបលួចធ្វើបាបពីក្រោយ នោះទំនងជា Lorenzo បុរសខ្មែរដែលធំធាត់ឡើងនៅអាមេរិកម្នាក់នេះ គួរតែមានស្មារតីប្រុងប្រយ័ត្នខ្ពស់ ប៉ុន្តែតាមការសង្កេតរបស់ចិត្រា គេហាក់មានអាការៈស្ងប់ស្ងាត់ជាងមុនទៅទៀត នៅពេលឈានចូល ដល់ការសន្ទនា។

ជំនួយការគេមិនបានមកអង្គុយជាមួយទេ។

«ប៉ូលិសមានភស្តុតាងបង្ហាញថាលោកបានណាត់ជួបជាមួយអ្នករងគ្រោះទាំងអស់នោះហើយ ក្រោយមកពួកគេក៏បាត់ខ្លួន! ត្រង់នេះទាមទារឲ្យមានការបកស្រាយច្បាស់លាស់មួយ!»

ស្នងការ Roy ចាប់ផ្ដើមការសន្ទនាបន្តពីលោកឌិត សាម៉ុន។

ចិត្រាដែលទទួលភារកិច្ចជាអ្នកកត់ត្រាពិតមែន តែគេទទួលអារម្មណ៍ដឹងថារយៈពេល១នាទីដំបូងដែលគ្រប់គ្នាចាប់ផ្ដើមអង្គុយចុះទល់មុខគ្នា ភាពស្ងាត់ស្ងៀមរបស់ម្ចាស់ផ្ទះម្នាក់នេះអាចពន្យល់ចេញស្រេចទៅហើយអំពីការមិនពេញចិត្តរបស់គេ។ ពិសេសមួយឡែកទៀតក៏ហាក់បង្ហាញពីភាពស្មុគស្មាញនៃភាគីទាំងសងខាងដូចគ្នា ព្រោះលោក ឌិត សាម៉ុន ព្យាយាមតាមវិធីទន់ភ្លន់ ឯស្នងការRoyប្រើអំណាចជាសមត្ថកិច្ច។

«ខ្ញុំណាត់ជួបស្រីៗ! វាជារឿងធម្មតារបស់មនុស្សប្រុសសម័យនេះ! អត់មានអីត្រូវបកស្រាយទេ!»

ឮសំឡេងតបរបស់ Lorenzo ចិត្រាងើបមុខសម្លឹងបុរសវ័យក្មេងដែលមានឈ្មោះល្បីនិងជាទីស្រមៃនៃនារីជាច្រើន។ សំឡេងគេរក្សាសព្ទបានស្រោល តាមបែបមនុស្សសង្គមជាន់ខ្ពស់ តែបង្កប់នូវអាកប្បកិរិយាក្រអឺតមួយជាសម្ងាត់។ មួយវិញទៀត គេពិតជាស្រស់សង្ហា សូម្បីតែក្នុងក្រសែភ្នែកមនុស្សប្រុសដូចគ្នា។

«ព្រោះវាជាការណាត់ជួបតាមរបៀបមនុស្សនៅលីវ គេនិយមធ្វើ!»

គេនិយាយបន្ថែមដោយសម្លឹងចំអកឲ្យកែវភ្នែកច្រណែនរបស់ស្នងការ Roy។ ចិត្រាសម្លឹងបុរសទាំងពីរដែលកំពុងគគ្រីតដាក់គ្នាក្នុង «ស្រោមជាអ្នកចេះដឹង មិននិយាយព្រួៗប៉ុន្តែចុកៗ» គេខ្លួនឯងក៏លបគិតស្ងាត់ៗក្នុងចិត្ត «សូម្បីតែកូនស្រីរបស់លោកឧត្តមសេនីយ៍ក៏បានដាក់ពាក្យទៅចូលរួមពិធីនោះដែរ តើ Roy ម្នាក់នេះចាញ់ចិត្ត Lorenzo កម្រិតណាទៅ បើដឹងថាគូដណ្តឹងខ្លួន...?»

លោកឧត្តមសេនីយ៍ដែលតាមពិនិត្យអាការៈបុរសនេះជាយូរមកហើយចាប់ផ្តើមកាត់ផ្តាច់បរិយាកាសមិនមិនគប្បីនេះដោយផ្តើមនិយាយ៖

«ជំនិត វីរៈ! លោកមានសិទ្ធិជួបអ្នកណាជារឿងរបស់លោក ប៉ុន្តែក្រោយពេលជួបលោក ស្រីៗទាំងនោះបានបាត់ខ្លួនបន្តបន្ទាប់គ្នា លោកគួរតែនៅមិនសុខចំពោះហេតុការណ៍នេះដែរ! ហើយខ្ញុំសង្ឃឹមថា លោកមានតម្រុយឬព័ត៌មានដែលត្រូវរាយការណ៍ប្រាប់ប៉ូលិស!»

ចិត្រាក្រឡេកទៅ Lorenzo សាជាថ្មី។

បុរសនោះពិតជាមានភាពមាំទាំនឹងមានជំនឿចិត្តលើខ្លួនឯងខ្ពស់ បានជាគេហាក់មិនមានបញ្ចេញអាការៈណាមួយឲ្យដូចជាកំពុងទោរទន់ទទួលកំហុសដូចដែលលោកឱត សាម៉ុន កំពុងលួចរិះគន់គេជាប្រយោលនោះសោះ។

ពិតមែនហើយ បើគេពិតជាមានប្រវត្តិណាត់ជាមួយនារីទាំងនោះមុនបាត់ខ្លួន ចុះតើហេតុអ្វីគេធ្វើមិនដឹងមិនឮចំពោះភាពរងគ្រោះរបស់ពួកនាង ហើយមិនព្រមសហការជាមួយប៉ូលិស?

មកដល់ចំណុចនេះ ស្នងការ Roy បន្ថែមមកផ្សងដោយមិនបង្អង់៖

«បើមហាវីនមិនសារភាព លោកគ្មានថ្ងៃប្រាប់ប៉ូលិសទេ ថាលោកជួបពួកនាងប៉ុន្មានម៉ោងប៉ុណ្ណោះមុនពេលម្នាក់ៗបាត់ខ្លួន!»

ជាទូទៅ ចិត្រាដឹងថាភាពតានតឹងនៅក្នុងពេលវេលាសាកសួររបស់ប៉ូលិសគឺ ភាគច្រើនគេមិនងាយទទួលបានចម្លើយស្មោះត្រង់ពីដំបូងៗឡើយ។ អ្នកឆ្លើយម្នាក់ៗរមែងតែងមានវិធីអូសបន្លាយពេលវេលា រហូតដល់អស់ផ្លូវគេចវេះទើបគេព្រមនិយាយពីការពិត។

ប៉ុន្តែករណី Lorenzo ពេលនេះមិនដូចអ្នកដទៃទេ គេផ្អែកខ្នង ក្រពាត់ដៃហើយចរចាតប ធ្វើវាហើក្នុងសព្ទសម្តីមួយៗ៖

«ខ្ញុំមិនមានទាក់ទងនឹងរឿងបាត់ខ្លួនអស់នេះ ឲ្យខ្ញុំទៅពន្យល់ឬរាយការណ៍អំពីអ្វី?»

«ចុះហេតុអ្វីលោកណាត់ជួបស្រីៗបន្តបន្ទាប់គ្នា ហើយសឹងតែរៀងរាល់ថ្ងៃ?»

ចិត្រាររភ្នែកសម្លឹងគ្រប់គ្នាម្តងម្នាក់ៗនៅក្នុងបន្ទប់នេះ។ គេឃើញជំនួយការវឌ្ឍនៈនៅឈរត្រេងត្រាងក្បែរជណ្តើរ។

អ្នកកំលោះងាកមករកម្ចាស់ផ្ទះនេះវិញ។ ទឹកមុខតារាសប្បុរសម្នាក់នេះ គ្មានត្រង់ណាបង្ហាញថាគេព្រមចុះចាញ់ស្នងការ Roy ឡើយ។ អាណិកជនសង្កត់ពាក្យមួយៗ៖

«លោកកំពុងជ្រៀតជ្រែកចូលសិទ្ធិផ្ទាល់ខ្លួនរបស់ខ្ញុំ! ខ្ញុំគួរហៅមេធាវីដែរទេ?»

Lorenzo ប្រើសំណួរបកបញ្ច្រាស ជំនួសឲ្យពាក្យចម្លើយហើយគេសម្លឹងស្នងការ Roy ហើយងាកមករកនាយកព្រហ្មទណ្ឌជាសញ្ញាថាគេមិនញញើតក្នុងការប្រឈមមុខនិងប៉ូលិសសក្តិធ្ងន់ៗទាំងនេះឡើយ។

ឧត្តមសេនីយ៍ ឌិត សាម៉ុន ពិនិត្យពិច័យលើកិរិយារបស់បុរសនេះមិនឲ្យបាត់ពីក្រសែភ្នែកចាប់តាំងពីលោកធ្លាប់បានយល់ស្របជាមួយចិត្រារួចទៅហើយថា Lorenzo ទំនងជាពុំមែនអ្នកពាក់ព័ន្ធពិតប្រាកដទេ។

ស្ថានភាពគេ ប្រាកដជាត្រូវបានអ្នកណាម្នាក់រៀបចំអន្ទាក់ធំៗ បំណងចង់ឲ្យគេជាប់ជុចរើខ្លួនលែងរួច។ ដូច្នេះបើចង់ស្វែងរកមុខអ្នកនោះ ទាល់តែធ្វើឲ្យតារាសប្បុរសនេះត្រូវស្ថិតក្នុងស្ថានភាពដូចជាជាប់ផុងមែនទែន។

«នៅពេលមហាវីនចាប់ផ្តើមប្រុងប្រយ័ត្ន ហើយលែងចង់សហការជាមួយលោក គាប់ជួនស្រាប់តែគេត្រូវរងការតាមលបសម្លាប់បំបិទមាត់! រឿងហេតុជួនគ្នាពេកហើយដឹង? មិនយូរប៉ុន្មានពិធីការរបស់គេឈ្មោះ Rose ដែលឧស្សាហ៍ឡើងចុះផ្ទះលោកដោយលួចលាក់ ពេលនេះក៏ស្រាប់តែបាត់ខ្លួន? ប៉ូលិសរកឃើញឡាននាងនៅក្រឡាប់ចោលក្រោមស្ពានខេត្តកណ្តាល! ហើយកំណត់ត្រាចុងក្រោយដែលប៉ូលិសមានក្នុងដៃគឺ នាងបានមករកលោកប៉ុន្មានម៉ោងប៉ុណ្ណោះមុនពេលបាត់ខ្លួនទៅ!»

Lorenzo ត្បិតតែនៅស្ងៀមលែងស្រដី តែអ្នកណាក៏អាចមើលដឹងដែរថាព័ត៌មានចុងក្រោយរបស់ Rose កំពុងធ្វើឲ្យចិត្តគេរង្គោះរង្គើ។

«បើពួកលោកពូកែមែន ទៅរកនាងឲ្យឃើញមក!»

គេនិយាយស្រាលៗ បន្ទាប់ពីស្ងាត់អស់មួយខណៈ។

ព្រោះតែអនាគតឪពុកក្មេកកំពុងតែមានវត្តមាននៅក្បែរនេះទេ ទើបស្នងការ Roy ខាំមាត់លេបកំហឹង ទ្រាំជាមួយពាក្យ «ពូកែមែន!» របស់អាណិកជន។

«តើលោកជួបមនុស្សស្រីប៉ុន្មាននាក់ ហើយម្នាក់ៗរយៈពេលយូរប៉ុនណា?»

លោក ឱត សាម៉ុន បោះសំណួរមក  ធ្វើឲ្យគ្រប់គ្នានៅត្រៀមចាំស្ដាប់ចម្លើយពីតារាសប្បុរស។

គេវិញក៏បញ្ឈប់ភ្នែកនៅត្រង់ឧត្ដមសេនីយ៍ ឱត សាម៉ុន ព្រោះឧត្ដមសេនីយ៍នេះសម្លឹងមកនាយដោយអ្វីម្យ៉ាងលាក់លៀមក្នុងខ្សែភ្នែក។ គេមិនទាន់ឆ្លើយ គាត់ក៏បន្ដមកថែម៖

«យប់មិញពេល Rose មករក លោកនិយាយពីរឿងអ្វី?»

Lorenzo មិនអាចនៅស្ងៀមមិនឆ្លើយនូវសំណួរដល់ទៅបីបានទេ។ នឹកឃើញដល់ Rose កាលណា គេក៏នឹកដល់សម្ដីនាងដែលកាលពីយប់ស្រូតមករកគេ ជាមួយការជជែកឲ្យដំណឹងដែលមានព្រមគ្នាទាំងការវិភាគផ្ទាល់លក្ខណៈសង្ស័យជ្រៅៗរបស់នាងឲ្យគេចេះប្រុងប្រយ័ត្ន  ហើយមើលទៅនាង ហាក់មានការឈឺឆ្អាលចំពោះខ្លួនពិតៗ។

«ខ្ញុំមកនេះចង់ប្រាប់ថា បើកម្មវិធីក្លែងក្លាយយប់នេះលោកជាអ្នករៀបចំ ឆាប់បញ្ឈប់វាភ្លាមព្រោះមុននេះមហាវីនខលមកសួរខ្ញុំ ហើយខ្ញុំដឹងថាប៉ូលិសនៅក្បែរគេ!» «នាងប្រាប់ប៉ូលិសអស់ហើយ រឿងដែលខ្ញុំបានជួបស្រីៗអស់ទាំងនោះ?» «ខ្ញុំមិនដែលគិតធ្វើបាបលោកទេ តែមហាវីន! ខ្ញុំមិនធានា!»

Lorenzo គិតចុះឡើង គេនៅតែគ្មានផ្លូវឯណានឹងកុហកប៉ូលិសបានពិតមែន អ៊ីចឹងហើយគេដាច់ចិត្តនិយាយ៖

«Rose មករកខ្ញុំ គេសួរខ្ញុំថាដឹងរឿងសមោសរម៉ោង៩យប់មិញដែរអត់?»

លោក ឱត សាម៉ុន មើលទៅក្មេងប្រុសម្នាក់នេះ ក៏កំពុងតែមិនចង់ពន្យារវែងឆ្ងាយដែរ ព្រោះថា ចម្លើយគេគ្មានឃើញចំណុចណាមួយគួរឲ្យសង្ស័យទាល់តែសោះ។

«ចុះលោកដឹងទេ?»

គាត់សួរខ្លីៗ តែគ្រប់គ្នាដឹងថា ឧត្តមសេនីយ៍សំដៅដល់កម្មវិធីក្លែងក្លាយកាលពីយប់មិញ។

Lorenzo គ្រវីក្បាលជំនួសចម្លើយ ហើយគេនិយាយមួយៗ៖

«ក្រោយមកពេលនាងចេញបាត់  ខ្ញុំយល់ស្របគំនិត Rose ដែលជាស់តឿនខ្ញុំថា អ្នកណាម្នាក់ដូចជាកំពុងតែប៉ុនប៉ងធ្វើអ្វីមួយទម្លាក់បន្ទុកមកឲ្យខ្ញុំ! អ៊ីចឹងហើយខ្ញុំនិងបងវឌ្ឍនៈខ្លាចនាងមានគ្រោះថ្នាក់ក៏ចេញទៅរកនាង!»

គេនៅស្ងៀមវិញ ធ្វើឲ្យគ្រប់គ្នាស្ងៀមស្ងាត់តាម រហូតដល់លោក ឱត សាម៉ុន ដកដង្ហើមធំ ហើយនិយាយ៖

«ម្នាក់នោះ លោកសង្ស័យថាអ្នកណា ហើយគេធ្វើបាបលោកដើម្បីអ្វី?»

គេមិនឆ្លើយ តែងើបមុខសម្លឹងមកគ្រប់គ្នារហូតដល់លោកឧត្តមសេនីយ៍ពោលបញ្ជាក់៖

«ប៉ូលិសទាំងពីរនៅទីនេះ សុទ្ធតែអាចទុកចិត្តបាន!»

ទោះយ៉ាងណា ស្នងការ Roy បង្ហាញភាពឆ្មើងកន្ទ្រើងលើផ្ទៃមុខ។

គេនិងអាណិកជន មើលទៅហាក់បីដូចជាធ្លាប់មានវិវាទនឹងគ្នា តែមិនដឹងរឿងអ្វី។ ចិត្រាតាមឃ្លាំពិនិត្យអាការៈពួកគេ ស្រាប់តែសំឡេង Lorenzo លាន់មកយឺតៗ៖

«កាលពីមុននេះ១០ឆ្នាំ ប៉ាធម៌ខ្ញុំក៏វិះនឹងត្រូវខូចឈ្មោះទទេ ដោយសារល្បែងដាក់អន្ទាក់នៅស្រុកខ្មែរនេះដែរ!»

ក្រៅពីជំនួយការវឌ្ឍនៈដែលឈ្ងោកមុខស្ដាប់គ្មានប្រតិកម្ម ចិត្រាគិតថាទីនេះគ្មានអ្នកណាដឹងថា បុរសអ្នកមានកំពុងនិយាយពីអ្វី អន្ទាក់អ្វី?។

ផ្ទុយទៅវិញ លោក ឱត សាម៉ុនឆ្លើយរ៉ុយហាក់គ្មានចម្ងល់៖

«មេធាវីជំនិត រួចខ្លួនបានវិញដោយសារគាត់ពិតជាមិនបានសម្លាប់ប្អូនធម៌ឈ្មោះណិចនោះ! ចំណែកលោកពេលនេះ ចង់រួចខ្លួនបានទាល់តែលោកពិតជាមិនមានពាក់ព័ន្ធនឹងការបាត់ខ្លួនរបស់ក្មេងស្រីៗអស់ទាំងនោះ!»

សម្ដីរបស់លោក ឌិត សាម៉ុន ស្ដាប់ចុះស្ដាប់ឡើងធ្វើឲ្យចិត្រាវិលវល់។

នាយងាកមករក Lorenzo សន្សឹមៗ ហើយសួរខ្លួនឯងក្នុងចិត្តទាំងមាត់ចំហផ្លុង។

«គេនេះត្រូវជាអ្វីនឹងមេធាវីជំនិត ក្នុងសំណុំរឿងចុងក្រោយដែលលោកពូខ្ញុំបានដោះស្រាយ?»

Lorenzo ទំនងជាខឹងនឹងសម្ដីចុងក្រោយរបស់ឧត្តមសេនីយ៍ បានជាគេស្រាប់តែក្រោកឈរវិញ៖

«ទីបំផុតខ្ញុំសហការច្រើនយ៉ាងនេះ លោកនៅតែគិតថាខ្ញុំពាក់ព័ន្ធការបាត់ខ្លួនឆ្កួតៗអស់នោះ?»

គេប្រហែលជាគិតថាខ្លួនខំទុកចិត្តមនុស្សចាស់ម្នាក់នេះ ហើយព្រមនិយាយការពិតចេញមកពីក្នុងចិត្តទាំងអស់ បែរជាបុរសនេះរុញគេឲ្យជាប់ផុងជាមួយភាសាវាយតម្លៃរបស់គាត់។

សំឡេងជំនួយការវឌ្ឍនៈលាន់មកសួរយោបល់ខ្សឹបៗ៖

«ឲ្យខ្ញុំខលទៅអាមេរិកទេ?»

អាណិកជនឆ្លើយតបវាហី ទាំងដៃគេរៀបចំអាវរបស់គេឲ្យមានសណ្ដាប់ធ្នាប់៖

«ប៉ាខ្ញុំគ្មានពេលមកអំពល់ជាមួយរឿងអត់ខ្លឹមសារអស់នេះទេ! ខ្ញុំដោះស្រាយខ្លួនឯងបាន!»

ចិត្រាធ្លាប់ដឹង ធ្លាប់អានពីសំណុំរឿង Z22 ដែលតួអង្គមេធាវីជំនិត មានចរិតជាអ្នកមានកប់ពពក មានទំនុកចិត្តខ្ពស់ និងមាក់ងាយមើលស្រាលសមត្ថភាពប៉ូលិសស្រុកខ្មែរ។ រហូតដល់ចុងក្រោយ គេបែរជាត្រូវបានជួយសង្គ្រោះឲ្យរួចខ្លួនចេញពីអន្ទាក់ ដោយសត្រូវបេះដូងជាអតីតគូដណ្ដឹងភរិយាខ្លួនឯង ដែលគេធ្លាប់តែដាក់ការសង្ស័យលើគាត់រហូតមក។

«ពូខ្ញុំអើយ! មេធាវីខ្មែរអាមេរិកដែលពូជួយ គេពូកែរកបានកូនធម៌ចរិតស្មើមេឃដូចការកត់ត្រាទុករបស់ប៉ូលិសជំនាន់មុនម្ល៉េះ?»

លោកឌិត សាម៉ុនគ្រហែមយកសំឡេងហើយក្រោកមកតាមម្ចាស់ផ្ទះ។ គាត់វាចាក្រោមទឹកមុខសៅហ្មងរបស់នាយ៖

«លោកមិនទាន់ប្រាប់ខ្ញុំនៅឡើយពីរឿងណាត់ជួបស្រីៗ អស់ទាំងនោះ!»

គេនៅស្ងៀម ទឹកមុខនៅតែសោះអង្គើយ តែប៉ូលិសចំណាស់មិនខ្វះចិត្តសាស្ត្រក្នុងការឈ្លេច បន្ថែមឡើយ៖

«មិញនេះលោកអះអាងថា មានអ្នកណាម្នាក់កំពុងតែចង់ធ្វើបាបលោក ហើយពេលនេះលោក មិនព្រមផ្តល់ចម្លើយ តើឲ្យប៉ូលិសធ្វើការដោយរបៀបម៉េចបាន!»

«ខ្ញុំនឹងហៅមេធាវីរបស់ខ្ញុំឲ្យជួបលោក!»

គេងាកមករកឧត្តមសេនីយ៍ជាមួយឫកពាខែងរ៉ែង មុនពេលនិយាយបង្ហើយ៖

«គេនឹងនិយាយរឿងទាំងអស់នោះជំនួសខ្ញុំ!»

Lorenzo ចាកចេញចុះមកក្រោមមុន ទាំងទទឹងទទែងដូចជាមានចេតនាបណ្តេញសមត្ថកិច្ច អ៊ីចឹងដែរ។

ប៉ូលិសទាំងបីដើរមកតាមក្រោយគេ ព្រោះថាការសន្ទនាមិនអាចបន្តទៀតបានទេ។

ឯជំនួយការវឌ្ឍនៈឆ្លេឆ្លាចុះឡើងមិនដឹងត្រូវធ្វើអ្វីមុន។

«ហៅមេធាវីយើងមក!»

គេបញ្ជាពីជាន់ក្រោម ធ្វើឲ្យអ្នកក្រោមបង្គាប់ឆ្លើយ «បាទ» យ៉ាងរហ័ស។

ពីក្រោយខ្នងគេ លោកឌិត សាម៉ុននិយាយខ្លី៖

«អរគុណដែលសហការ!»

Lorenzo មិនមាត់អ្វី ហើយគេឈរបែរខ្នងសម្លឹងទៅក្រៅផ្ទះតាមបង្អួចកញ្ចក់។ ប៉ុន្តែទោះបីជាមើលពីក្រោយខ្នងទៅ ក៏លោក ឌិត សាម៉ុនអាចយល់បានពីទំហំទុក្ខព្រួយរបស់គេដែរ។

នៅតាមផ្លូវចេញមកវិញ ស្នងការ Royឡើងឡានរបស់គេ ចំណែកចិត្រាទៅជាមួយលោកឌិត សាម៉ុន។ មានកូនប៉ូលិសផ្សេងទៀតបានបើកឡានមកចាំទទួលជាស្រេច។

«ខ្ញុំនិងចិត្រាមានការផ្សេងត្រូវធ្វើ លោកទៅស្នងការមុនចុះ!»

គាត់ប្រាប់ទៅស្នងការ Roy ដែលចំហមាត់ឈរមើលភាពស្និទ្ធស្នាលនៃបុរសចាស់ក្មេងទាំងពីរ។

នៅលើឡានពួកគេគ្មានអ្វីនិយាយគ្នាទេ ប៉ុន្តែចូលដល់ផ្ទះសឹងមិនទាន់ គាត់ចាប់ផ្ដើមសួរនាយ ៖

«ចិត្រា!»

«បាទទាន!»

«លោកយល់យ៉ាងណាចំពោះចម្លើយ Lorenzo?»

នាយគិតបន្តិចពេលឮសំណួរ ប៉ុន្តែចិត្តនៅតែវិលវល់។ ដំណឹងពីឯកមាននិងផានូមិនទាន់មាន ចំណែក អ្នកកាងសាលាគឺនាយឈុនរាជរឹតតែគ្មានស្រមោល។ នៅទីនេះ អ្នកបាត់ខ្លួនទី៥ បានកើតឡើងទៀតហើយ គឺប៉ះចំមេពិធីការរបស់សមោសរនោះផ្ទាល់ ចំណែកសុវត្ថិភាព អមរាដាក៏ជាសំណួរធំមួយផ្សេងទៀត។

គេនិយាយមួយៗ ទាំងគិតបណ្ដើរឆ្លើយបណ្ដើរ៖

«ខ្ញុំយល់ថា Lorenzo មិនបាននិយាយកុហកទេ! ប៉ុន្តែគេនិយាយមិនទាន់អស់!»

«លោកយល់ថាគេនៅពីក្រោយការចាប់ខ្លួនស្រីៗ អស់ទាំងនោះ?»

«ខ្ញុំចាំជួបមេធាវីគេសិន! »

លោក ឱត សាម៉ុន ញញឹមទះស្មានាយ៖

«លោកដូចប៉ូលិសស៊ើបអង្កេតដែលមានបទពិសោធន៍ច្បាស់លាស់ណាស់!»

នៅខាងក្រៅទ្វារ ស្រីតូចអមរាដាដែលបានមកដល់ព្រោះតែចង់ប្រគល់វត្ថុម្យ៉ាងឲ្យអង្គរក្សដ៏វវល់ម្នាក់នេះ នាងនៅសំចតក្បែរទ្វារដើម្បីលបស្ដាប់ការសន្ទនា។

មើលពីក្រៅទៅ អង្គរក្សម្នាក់នេះមិនសមជាអ្នកសាច់ការធំដុំទេ ចុះម៉េចក៏ប៉ាខ្លួនទុកចិត្តហើយធ្វើការសំខាន់ៗជាមួយគេ?

នាងនឹកទៅដល់ស្ថានភាពគ្រោះថ្នាក់កាលពីម្សិលមិញ នឹកដល់កាយវិការនិងសម្ដីទាំងឡាយដ៏ហ្មត់ចត់របស់គេ «អត់ទេ ខ្ញុំត្រូវទៅជាមួយអ្នកនាង!» «ខ្ញុំឲ្យបងឯងធ្វើនេះ បងឯងទារធ្វើ

នោះ!» «ខ្ញុំគិតពីសុវត្ថិភាពអ្នកនាង!» «បងឯងខ្លាចអី! ខ្ញុំស្គាល់ពូពិសិដ្ឋច្បាស់ គាត់អ្នកតេមកផ្ទាល់!» «មិនមែនលោកឧត្តមសេនីយ៍ទូរសព្ទមកផ្ទាល់ទេ?»

សំឡេងគេដែលស្រែកឮៗទៅកាន់សន្តិសុខ «នាំអ្នកនាងចូលផ្ទះ!» និងស្នូរគ្រាប់កាំភ្លើងនៅតែលាន់រងំរញ្ជួយអារម្មណ៍ស្រីតូច។ ទោះបីថា នាងជាកូនស្រីប៉ូលិសនាងមិនដែលខ្លាចអ្វី តែនាងនឹកឃើញដល់ពាក្យ «ស្រីនោះត្រូវយកមកទាំងរស់!» របស់ពួកជនមិនស្គាល់ប្រវត្តិ ធ្វើឲ្យនាងអនិច្ចាថាមកដល់ថ្មើរណេះ តើវាសនាខ្លួនទៅជាអ្វីទៅ ហើយប្រសិនពេលនោះអង្គរក្សម្នាក់ដែលនាងធ្លាប់តែធុញទ្រលាន់មិនប្តូរជីវិតមកជួយខ្លួន។

នាងឈរទ្រឹង នឹកឃើញដល់មិត្តសម្លាញ់...

«ផានូ ពេលនេះឯងមានរឿងអីទៅ?»

គេស្រាប់តែបើកទ្វារដើរចេញមក ហើយគាំងជើងពេលឃើញនាងនៅឈរភ្លឹកស្រពោនក្បែរទ្វារ។

ស្រីស្អាតមិនដឹងត្រូវនិយាយអ្វី ក៏សម្លឹងមុខនាយភ្លឹះៗ ទុកឲ្យនាយសម្លឹងមកប្រេងមួយកូនដបលើដៃនាង។

បើមិនឃើញរបស់នេះ គេមិនដឹងថាខ្លួនឯងនៅឈឺដៃដែលវាយបំបុកកញ្ចក់ឡាននោះទេ។

«បងឯងលាបប្រេងអត់?»

នាងជាអ្នកនាងធំ ជាព្រះនាងម្ចាស់តែមួយអង្គក្នុងភូមិគ្រឹះនេះ ប្រសិននាងមិនព្រោះតែសម្បជញ្ញៈជេរស្តីដែលកន្លងមកតែងតែមិនពេញចិត្តនាយ ចុងក្រោយបាននាយយកជីវិតទៅរងដើម្បីសុវត្ថិភាព នាងម៉េចនឹងមកបង្ខំចិត្តធ្វើអំពើល្អមួយ គួរឲ្យបេះដូងបុរសកើតកក់ក្តៅបែបនេះបាន។

«ដៃខ្ញុំលែងអីហើយទាន!»

គេឆ្លើយដោយសំឡេងស្រាលៗ ទប់ស្កាត់ភាពទោរទន់របស់បេះដូង កុំឲ្យខាងស្រីមើលឃើញបាន។

«ឲ្យប្អូនលាបឲ្យទៅ!»

លោកឱត សាម៉ុននិយាយបន្តពីនាយ ធ្វើឲ្យនាយមីងមាំង។ បុរសចំណាស់ចាកចេញមកក្រៅដោយហុចដៃធ្វើសញ្ញាឲ្យប្រុសស្រីទាំងទ្វេចូលទៅអង្គុយក្នុងបន្ទប់ធ្វើការរបស់គាត់។

ពេលដែលចិត្រានៅទ្រឹង ព្រោះមិនដឹងថាអ្វីទៅដែលឧត្ដមសេនីយ៍កំពុងគិត គាត់ធ្វើជានិយាយបន្ថែមៈ

«រៀបបាយហើយនៅកូន? ប៉ាទៅញ៉ាំមួយម៉ាត់!»

នាងឆ្លើយទីទើរទាក់ៗៈ

«ចាស៎! នៅបន្ទប់បាយប៉ា!»

គាត់ឮហើយ ក៏ងាកមកស៊ីញ៉ូនាយៈ

«លាបដៃសិនទៅចាំទៅហូបតាមក្រោយ!»

បុរសចំណាស់ថាហើយ រួសរាន់ចាកចេញទៅបាត់ហាក់បីដូចជាគាត់មានចេតនាទុកឱកាសនេះឲ្យក្រមុំកំលោះបានយល់ចិត្តគ្នា។

«ពីណាថាខ្ញុំលាបប្រេងឲ្យបងឯង!»

នាងនិយាយអៀនអន់ ហើយថ្ពាល់ទាំងគូក្រហមទុំ តែនាងក៏មិនទៅណាទុកឲ្យបុរសនេះលង់សម្លឹងសម្រស់ស្រីស្អាតភ្លឹកមួយខណៈ។

ទោះជាយ៉ាងណាក៏ដោយ គេមិនអាចលង់ភ្លឹកបានយូរពេកនោះទេ។ ដូច្នេះហើយ ចិត្រាងាកមុខចេញ ធ្វើតាមឋានៈរបស់ខ្លួនៈ

«ខ្ញុំលាបខ្លួនឯងបានហើយ!»

គេលូកដៃទៅប្រុងទទួលដបប្រេង តែអមរាដាញញឹមមិនហ៊ានសម្លឹងមុខនាយទេ។ ដៃនាងក្ដោបដបប្រេងជាប់បញ្ជាក់ថាមិនប្រគល់ឲ្យ តែមាត់អ្នកនាងផ្ទះឧត្ដមសេនីយ៍ និយាយរ៉ាវៈ

«ណ្ហើយខ្ចិល! ដៃបងឯងឈឺផង ចាំខ្ញុំលាបឲ្យក៏បាន!»

ចិត្តមនុស្សស្រីប្ដូរភ្លឺបភ្លែតដូចផ្លេកបន្ទោរ ធ្វើឲ្យបុរសឋានៈតូចតាមមិនចង់ទាន់ មិនត្រឹមតែប៉ុណ្ណឹងនាងលូកដៃមករុញនាយឲ្យចូលទៅក្នុងវិញ ហើយអង្គុយទៅលើសាឡុង។

បុរសរាងមាំមួនដែលសូម្បីតែកញ្ចក់ឡានរឹងដូចពេជ្រនៅតែវាយបំបែកបាន ពេលនេះបែរជាទន់ល្មើយទាំងកាយ ចិត្ត បេះដូងនៅក្រោមការប៉ះពាល់របស់ស្រីស្អាត។

នាងឈ្ងោកមុខដែលក្រហមព្រឿងៗ ហើយប្រើម្រាមវែងៗស្ដួច មកលាបប្រេងលើដៃនាយ អង្គរក្សថ្នមៗ ធ្វើឲ្យបុរសក្រឡេកទៅឃើញតែសក់ពណ៌ខ្មៅរលោងនិងកញ្ចឹងកសហ្មត់។

បេះដូងនាយច្រងាប់ច្រងិលអាណិតខ្លួនភ្លាម។

ហេតុអ្វីយើងត្រូវមកមានអនុស្សាវរីយ៍បែបនេះជាមួយទេពធីតា។ យើងនឹងគេងនឹកនាង នឹកពេលវេលានេះពេញមួយជាតិហើយមែនដែរទេ?

នាងស្ដាប់ឮសង្វាក់បេះដូងនាយដែរក៏មិនដឹង បានជាស្រីស្អាតទប់ដៃវិញហើយឱនមុខគិត។ គេនិយាយដាក់នាងបំបាត់បរិយាកាសស្ងាត់ស្ងប់នេះចោល៖

«ខ្ញុំលាបខ្លួនឯងបាន!»

នាងស្រាប់តែញញឹមស្រស់ ហើយងើបមុខមកវិញដោយសួររ៉ាវ៖

«ម៉េចបងឯងខ្លាំងម៉េះ យកដៃទទេវាយបំបែកកញ្ចក់ឡានបាន?»

គេដឹងថានាងគ្រាន់តែសួរបន្លប់ប៉ុណ្ណោះ។ នាងអៀនចំពោះនាយ បានជានាងខំបន្លប់ហើយកែវភ្នែកនាងក្រឡង់ៗ រឹតតែធ្វើឲ្យបុរសនេះបានចិត្ត សម្ងំមិននិយាយ ហើយសម្លឹងនាងដោយកែវភ្នែកស្រទន់។ មានតែមនុស្សដែលស្រលាញ់យើងប៉ុណ្ណោះ ដែលអាចប្រើស្នាមញញឹមក្នុងកែវភ្នែកជំនួសឲ្យស្នាមញញឹមនៅលើបបូរមាត់បាន។ គ្មានអ្នកណាធំពេញវ័យហើយ មើលមិនដឹងភាសាស្នេហាក្នុងកាយវិការភេទផ្ទុយនោះឡើយ លើកលែងតែគេធ្វើមិនដឹង។

នាងដឹងហើយនៅតែធ្វើពើ ហើយសង្ងើញសួរព្រោះបេះដូងកំពុងញាប់ញ័រ៖

«បងឯងឮខ្ញុំសួរអត់?»

គេដកខ្សែភ្នែកដែលពេញទៅដោយកម្ដៅស្នេហ៍ចេញពីវង់ភក្ត្រស្រី ជាមួយវាចាសម្ងាត់បន្ទោសបេះដូងខ្លួនឯង៖

«អាកូនទន្សាយ មិនស្គាល់ឋានព្រះចន្ទ!»

នាងចាប់ផ្ដើមរិុកង៉ក់៖

«អីក៏សម្ងាត់ម៉េះ? ប៉ុណ្ណឹងក៏មិនប្រាប់ដែរ!»

ពេលស្រីស្អាតក្មេងខ្ចីមករិុកង៉ក់ក្បែរកាយ តើនាយប៉ូលិសចិត្តដែកថែបណាដាច់ចិត្តមិននិយាយបាន?

គេវាចាមួយៗស្រាលក្នុងសូរសំឡេងស្រទន់របៀបជាភាគីចាញ់ស្នេហ៍៖

«រៀននៅសាលាប៉ូលិស!»

នាងកាន់តែបើកភ្នែកមូលក្រឡង់ហើយឈប់លាប អង្គុយមកកៀកហើយសួរស្លុងតែម្ដង៖

«ឮប៉ាថានៅនុះហាត់អាក្រក់ៗណាស់ អ្នកខ្លះទទួលមិនបានក៏បាក់កម្លាំងយកតែម្ដង មែនអត់បង?»

ចិត្រាញញឹមដៀងសម្លឹងភក្ត្រស្រទន់ ទន្ទឹមពេលដែលអនុស្សាវរីយ៍ចាស់កម្រើកមកហាក់នៅថ្មីៗ។

«ប្អូនខាងណោះ ចូលរៀនដែរអី?»

«អង្គរក្សផ្ទាល់ខ្លួន! ជាអង្គរក្សទេបាទ!»

«អត់អីទេ! បងដឹងមួយរយៈនេះភ្នំពេញមានរឿងអសន្តិសុខច្រើន! តែម៉េចក៏មិនរកកន្លែងអង្គុយ ម៉ោងរៀននៅវែងទៀតណា!»

«វិន័យសម្រាប់អង្គរក្ស មិនអាចអង្គុយពេលបំពេញការងារទេបាទ!»

«អូខេ អាចថា ប្អូនរកកន្លែងដែលអាចសមគួរជាងនេះក៏បាន! ឬមួយ អាចអ៊ីចេះទេ ចូលមកក្នុងសាលមក កុំនៅក្បែរបង្អួច!»

«ភារៈជាអង្គរក្ស ចៅហ្វាយនៅត្រង់ណា ត្រូវនៅត្រង់ណោះ! ពេលឈរការពារ មិនឲ្យឈរពីមុខ មិនឲ្យនៅពីក្រោយ មិនឲ្យនៅចំហៀងកៀកជាងមួយម៉ែត្រ!»

«មកអង្គុយលើក្បាលខ្ញុំហ្នឹងក៏បាន!»

គេសើចពេលនឹកឃើញត្រង់ណោះ។ ពេលនេះទេពអប្សរ ប្រែមកស្និទ្ធស្នាលអង្គុយកៀកសែនកៀកហើយជជែកប្រៀបបីដូចមិនធ្លាប់មានរឿងអ្វីជាមួយគ្នាពីមុនមកសោះ។

កែវភ្នែកនាងទាំងទ្វេក្រឡង់ៗ រង់ចាំទទួលពាក្យចម្លើយ ធ្វើឲ្យនាយឆ្លើយបន្ថែមស្រាលៗក្នុងសភាពជាសុភាពបុរស៖

«ការបង្ហឹកនៅសាលាប៉ូលិសមានចែកជាក្រុម ជាថ្នាក់តាមសភាពកម្លាំងរាងកាយ តួនាទី! អ្នកណារត់មិនរួចគេមិនបង្ខំឲ្យទៅជួរទីមួយទេ!»

«ស្អីទៅជួរទីមួយ!»

«គឺក្រុមឈានមុខ ជាក្រុមដែលមានវិញ្ញាសាមហាពិបាក ដែលអ្នកធម្មតាៗមិនគិតថាយើងធ្វើបាន!»

នាងបែរមុខមករកនាយ កៀកសែនកៀក ប៉ុន្តែបុរសយល់ថាសភាពរបស់នាងគឺមិនមែនស្រលាញ់នាយទេ តែចាប់អារម្មណ៍សមត្ថភាពប្រយុទ្ធរបស់នាយ។

«ចង់ហាត់មែន?»

គេសួរឌឺ នាងស្រាប់តែងក់ក្បាលភ្លាមហើយងក់យ៉ាងញាប់។ បុរសដកដង្ហើមធំហួសចិត្ត។

ភាគទី២៧

ស្មានថាបុប្ផាក្បែរដៃក៏កំពុងតែមានចិត្តដូចយុវវ័យនានាដែលផ្សារភ្ជាប់ចរន្តស្នេហ៍ទៅវិញទៅមកដោយការយល់ចិត្ត ដឹងអីអ្នកនាងដែលធ្លាប់តែត្រូវបានគេទំយើ នៅតែជាអ្នកនាងដែលមិនស្គាល់ស្នេហាស្គាល់តែការសប្បាយ។

«វាមិនសប្បាយទេអ្នកនាង!»

អ្នកនិយាយទាំងអាក់អន់ចិត្ត ហើយក្រោកចោលកៅអី ដឹងអីដៃទន់ល្វក់របស់ស្រីស្អាតលូកមកចាប់នាយឃាត់។ ហួសចិត្តដែលនាងដៃដល់មកប៉ះប្រុសកំលោះ ដោយមិនអាសូរសម្រែកបេះដូងនាយ ថែមទាំងពេលនេះស៊ីញ៉ូភ្នែកជាសញ្ញាបញ្ជាឲ្យគេអង្គុយចុះមកវិញទៀត។

សុទ្ធតែលេងកាយវិការបញ្ឆោជំនួសសម្ដីរបៀបប៉ូលិសទៀត។ ចំជាមហាកូនស្រីប៉ូលិសមែន! គេធ្វើមុខឱដងរបៀបមិនរីករាយ ហើយត្រឡប់អង្គុយចុះមកវិញ។

សម្ដីនាយលាន់មកភ្លេចឋានៈខ្លួន៖

«ស្មានថាមានគេដឹងគុណតិចតួច ដឹងអីមកចង់ប្រើមនុស្សរបួសឲ្យបង្រៀនក្បាច់គុនវាយតប់ទៀត!»

ស្រីស្អាតតាមសម្លឹងនាយទាំងឆ្ងល់ ដែលឃើញសុភាពបុរសចេះងរ។

«ពីណាថាឲ្យបងឯងបង្រៀនពេលឥឡូវហ្នឹង! គ្រាន់តែនិយាយទុកសោះ!»

នាងសម្លក់នាយទាំងមាត់ញញឹម។ ពេលខាងប្រុសដៀងភ្នែកមកយ៉ាងស្រទន់ នាងក៏សួរបន្ថែមទៀត៖

«កាលហ្នុង បងឯងសិស្សលេខមួយមែនអត់?»

គេនៅតែមិនឆ្លើយ ព្រោះវក់នឹងសម្រស់ស្នាមសើចចិញ្ចាចរបស់នាង។

«ហើយឈឺដៃសោះ បងឯងទៅជាគ?»

នាងបន្ទោសរំអុកធ្វើឲ្យបុរសសើចក្អឹកៗ។

«នៅសាលាប៉ូលិសហ្នឹងណ៎ា! បងឯងបានលេខប៉ុន្មាន?»

«អត់ប្រាប់! អ្នកនាងដឹងតែថាអង្គរក្សនេះមិនមែនលេខមួយទៅបានហើយ!»

នាងចងចិញ្ចើម៖

«ហើយមិនទាន់លេខមួយខ្លាំងប៉ុណ្ណឹងហើយ! ចុះអ្នកលេខមួយ?»

«អាមាន!»

គេនិយាយតិចៗហើយក៏លែងញញឹម។ បបូរមាត់នាងក៏រុះរោយស្នាមញញឹមទៅដូចគ្នាដែរ ព្រោះពេលគេនឹកឃើញដល់ឯកមាន នាងក៏ស្រាប់តែនឹកឃើញទៅដល់ផានូ...

ក្នុងបរិយាកាសស្ងប់ស្ងាត់ នាងចាប់ដៃគេ៖

«បងឯងដឹងថាផានូនៅឯណាអត់?»

ទ្រូងនាយតឹង តែនាយមិនចង់បន្តវាទៅឲ្យនារីនេះ បានជានិយាយកាត់នាង៖

«កុំភ័យ! អ្នកនាងផានូនៅជាមួយអាមាន! គាត់មិនអីទេ!»

«បងឯងប្រាកដអត់?»

នាងសួរហើយបបូរមាត់ចាប់ផ្ដើមញ័រ...

**វគ្គ ទន្សាយបានក្បែរចន្ទ**

ស្គូរឡានរោទ៍លាន់ប៉ះគ្នាកក្រើកមេឃ ធ្វើឲ្យផានូតោងដៃឯកមានជាប់ ហើយបិទភ្នែកទាំងសងខាង ទោះបីជាជើងនាងនៅតែបន្តរត់ក៏ដោយ។

នាងរត់កាន់តែលឿនតាមដែលអាចធ្វើទៅបាន ហើយក៏មិនដែលនឹកឃើញថាខ្លួនរត់បានលឿនដល់ថ្នាក់នេះដែរ។ សម្រាប់មនុស្សស្រីជាអ្នកនាងនៅផ្ទះធំ មិនដែលលូនកាត់ព្រៃឬវារឡើងភ្នំ ពេលនេះជើងជាន់អីខ្លះក៏មិនដឹង។ នាងដឹងតែប្រឹងរត់រន្ថើន ទៅតាមបាតដៃក្ដាប់នាំរបស់អង្គរក្សចំណាប់ រត់គ្មានដឹងទិសតំបន់មុខក្រោយខ្ពស់ទាប ហើយចុងក្រោយក៏ទន់ជើងអស់កម្លាំងល្វើយពេលឮរថយន្តប៉ះគ្នាកក្រើកស្បៃរាត្រី។

រត់មកចម្ងាយឆ្ងាយហើយ សន្ធឹកឡាននៅតែឮមកខ្ទរបាន តើវាសនានាយឈុនរាជ បងប្រធាននិស្សិតនឹងក្លាយទៅជាយ៉ាងណា?

នាងយំសសឹក មុនពេលរបូតដៃពីនាយ ហើយបណ្ដោយរាងកាយឲ្យរមៀលធ្លាក់ រមូរជាច្រើនជុំ ទៅតាមតំបន់ដែលទំនងជាជម្រាលច្រាំង។ ដោយការធ្លាក់ចុះរហ័សពេក មេឃក៏ងងឹត រីឯចិត្តក៏រន្ធត់ពេក នាងលែងដឹងថាអាចជួយខ្លួនឯងវិធីណាបាន មានតែបណ្ដោយឲ្យរាងកាយរបូតទាំងមាត់ស្រែកយំ។

គេមិនដឹងមកដល់មុននាងយ៉ាងម៉េចបាន បានជាពេលនេះប្រអប់ដៃដ៏រឹងមាំដដែលរបស់ Hacker បានថ្ពក់ចាប់នាងជាប់សាជាថ្មី បញ្ឈប់ការរមៀលធ្លាក់។ ឯកមានទាញផានូយឺតៗឡើងពីទីជម្រាល។

«ទូរសព្ទខ្ញុំជ្រុះបាត់ ហើយ!»

នាងនិយាយផងយំអណ្តឺតអណ្តកផង។

Hacker ដកដង្ហើមធំ។ គេចងខ្សែមួយលើ-កដៃនាង ដែលផានូមិនអាចមើលឃើញតែនាងអាចទាយដឹងថាជាខ្សែស្បែកជើង។

«កុំឲ្យវង្វេងគ្នា!»

ប៉ូលិសនិយាយខ្សឹបៗ ប្រាប់អ្នកនាងអភិជន ទាំងរវៃភ្នែកប្រឹងជ្រែកទីងងឹត ស្វែងយល់ទិសតំបន់។

សត្វយំលាន់ឮសំឡេងមករញ៉េររញ៉ៃ ប៉ុន្តែសន្ទឹកឡានមិនបានឮទៀតទេ។

«យើងធ្លាក់ជម្រាលឆ្ងាយដល់ណាទៅ បានជាលែងឮអ្វីទាំងអស់?»

គេគិតក្នុងចិត្តម្នាក់ឯងទាំងដឹកដៃស្រីស្អាតដើរមួយៗ ស្វែងរកក្រែងប្រទះប្រភពពន្លឺភ្លើងចោលជះមក។

«ឈាម!»

នាងនិយាយតិចៗ តែរអាក់រអួល។

គេដឹងថានាងប្រហែលជាកកិតរបួសពេលធ្លាក់ចុះមុននេះ។ ចិត្តគេពិបាកភ្លេចគិតដល់ខ្លួនឯងពេលឮថាមនុស្សស្រីដែលគួរឲ្យស្រលាញ់ម្នាក់នេះឈឺចាប់។ ដៃរាវហោប៉ៅរកទូរសព្ទដែលប្រាកដថាបានស៊កមកមុនចេញពីឡានពេលនេះ គ្មានឃើញដូចគ្នា។

«ទ្រាំបន្តិច! យើងគង់តែរកគេជួយឃើញទេ!»

គេបញ្ឈប់ជំហានហើយព្យាយាមសម្គាល់ទីនេះ។ ព្រះចន្ទឃាងបាត់ហើយ ផ្កាយមួយក៏អត់។ បើយប់នេះមិនភ្លៀងចាត់ទុកថាមេឃមេត្តាទៅចុះ។

ឯកមានងាកមកសម្លឹងផានូ ព្រោះអាងថាមើលយ៉ាងណានាងគង់តែមិនសម្គាល់ដឹង ព្រោះកំពុងភ័យនឹងភាពងងឹត ភ័យនឹងពពួកល្មូនជាងអ្វីគ្រប់យ៉ាង។

«ទ្រាំបានអត់អូ្ន!»

គេខ្សឹបសួរតិចៗ ហើយផ្លេកបន្ទោរមួយឆ្វាចបានបណ្តាលឲ្យគេប្រទះឃើញផ្ទៃមុខសើមជោគទៅដោយទឹកភ្នែករបស់នាង។

មួយឆ្វាចនោះ អាចនាំមកនូវដំណក់ទឹកភ្លៀងដែលជាក្តីទុក្ខថ្មីមួយជាន់ទៀត ប៉ុន្តែគេបែរជាមិនខ្វីខ្វល់ព្រោះរវល់ភ្លឹកជាមួយនឹងសម្រស់ ច្រមុះរាងតូចស្រួច និងកែវភ្នែកស្រទន់ ត្រចៀកតូចៗរបស់នារីនេះ។ នាងនៅតែមានក្លិនក្រអូបដូចកំណប់ទឹកអប់ដែលមិនចេះរីងស្ងួត។

ទឹកភ្នែករបស់នាងបានឈប់ហូរតែវានៅកកជាប់ថ្ពាល់ដែលស្លេក។ ពន្លឺមួយឆ្វាចនេះល្មមឲ្យ ឯកមានវិលវល់ ដូចជាបាល់ត្រូវគេទាត់ចុះឡើងមិនអាចកំណត់ខ្លួនឯងថាយប់នេះសំណាងល្អ ឬអាក្រក់ឲ្យពិតប្រាកដ?។

«ខ្ញុំចង់ទៅផ្ទះ!»

គេភ្ញាក់ខ្លួនមកវិញ។

នាងលើកដៃម្ខាងចង្អុលទៅប្រភពផ្សែងហុយខ្ពួលលើអាកាសនៅឆ្ងាយសន្លឹម។

«បងឈុនរាជពិតជាជួយជីវិតខ្ញុំពិតមែន!»

នាងនិយាយបណ្តើររអាក់រអួលបណ្តើរ ធ្វើឲ្យបុរសនេះកើតចិត្តច្រណែន។ «ចុះអាម្នាក់ឈរជិតនេះ?» គេគិតទោមនស្សម្នាក់ឯងតែមិននិយាយស្តី។

ចុងដៃនារីនេះនៅតែត្រជាក់ល្ហុកក្នុងបាតដៃនាយ ធ្វើឲ្យបុរសHackerទប់ចិត្តមកវិញថា នាងកំពុងភិតភ័យតក្កមា ទើបនាយមិនត្រូវប្រកាន់អ្វីច្រើននោះ។

«បងឯងជូនខ្ញុំទៅផ្ទះវិញណាឯកមាន!»

Hacker ហាក់មានអារម្មណ៍ថារំភើបចិត្ត។ នាងស្គាល់ឈ្មោះច្បាស់ម៉េះ?

រាងកាយនាងរលំតិចៗទ្រេតមកលើនាយតាមកម្លាំងខ្យល់រាត្រីកាល ទោះបីជានាងប្រឹងទប់ឡើងវិញប៉ុន្មានដងហើយក្តី។ គេដឹងថានាងកំពុងតែហាត់នឿយមែនទែនហើយ។

«តាំងស្មារតី! យើងត្រូវស្រូតចេញពីកន្លែងនេះ! ពួកនោះរកយើងមិនឃើញ គេច្បាស់ជាតាមមក!គ្រោះថ្នាក់មិនទាន់ទៅឆ្ងាយទេ!»

គេនិយាយរួចក៏បន្ថែមលោមចិត្តនាង៖

«តែមិនបាច់ភ័យទេ! វាមិនអីទេ!»

គេទាញនាង ហើយបន្តដើរដោយរំពឹងលើពន្លឺព្រិលៗពីជើងមេឃឆ្ងាយ។

«វាលស្រែនេះធំម្ល៉េះ? មិនសមថាគ្មានភូមិ!»

នាងលែងមាត់លែង-ក។ នាងទំនងជាហត់ពេកឬខ្លាចពេកតែប៉ុណ្ណោះ។

គេបត់ទៅឆ្វេង ទាំងដែលនាងមិនដឹងថាគេសម្គាល់លើអ្វីក្នុងការកំណត់ទិសដៅនោះឡើយ។

តែផានូរឹតតែគ្មានកម្លាំងសួរ។ ជើងនាងជាន់អ្វីម្យ៉ាង នាងក៏ឈប់។

«ឯកមានខ្ញុំដូចជាជាន់ប្រអប់បាយ! អ្នកភូមិនៅក្បែរៗនេះ!»

គេបម្រុងឱនរាវរកមើល ពន្លឺភ្លើងពិលបាញ់មកចំកណ្ដាលមុខនាយ ធ្វើឲ្យនារីខ្ទប់មុខភ័យ ចំណែកឯកមានប្រឹងជម្នះភ្នែកសម្លឹងប្រឆាំងតតាំងនឹងពន្លឺ ព្រោះចិត្តគេពេញដោយក្ដីសង្ឃឹម។

សំឡេងគ្រោតគ្រាតមួយគំហកមកពីចម្ងាយ៖

«អាណាគេ?!»

ជាសំឡេងមនុស្សប្រុស។ ឯកមានមិនទាន់ដឹងថាត្រូវឆ្លើយតបរបៀបណា ស្រាប់តែបុរសនោះជះភាសារដីនមកប្រាវទៀត៖

«អ្ហែងពីម្សិលម៉្ងៃដែលលួចជ្រូកអញ?»

«មិនមែនខ្ញុំទេពូ!»

គេឆ្លើយតបភ្លាមព្រោះចិត្តបារម្ភឡើងវិញ។ ស្ងាត់លែងមានសំណួរ មានតែពន្លឺពិលដែលរំកិលចូលមកកាន់តែកៀក។ គេនិយាយបន្ថែម៖

«ជួយខ្ញុំផងពូ! ខ្ញុំត្រូវចោរតាមធ្វើបាប!»

**វគ្គ វាសនាឈុនរាជ**

ឈុនរាជ ធ្លាប់មានក្តីសុបិនថា នឹងធ្វើជាប៉ូលិសក្រុងដ៏មានកេរ្តិ៍ឈ្មោះម្នាក់។ រូបរាងនិងស្ថានភាពគ្រួសារគេ ដែលគ្មានប៉ាដោយសារគាត់បានបោះបង់ចោលនាយហើយរៀបការជាមួយនារីផ្សេង ធ្វើឲ្យក្មេងម្នាក់ដែលមានរូបរាងតូចទាប តាំងចិត្តថានឹងធ្វើខ្លួនឲ្យក្លាហានជាមនុស្សដែលមានកាយសម្បទាខ្ពស់ ដើម្បីការពារថែទាំអ្នកម្តាយរបស់ខ្លួនទៅអនាគត។

ចុងក្រោយឪពុកបានទទួលស្គាល់គេហើយទំនុកបម្រុងការសិក្សានៅមហាវិទ្យាល័យឯកជនដែលជាកម្មសិទ្ធិរបស់គាត់ផ្ទាល់។ នេះជាឱកាសឲ្យឈុនរាជរៀបចំផែនការក្លាយជានិស្សិតល្បីជាងគេក្នុងសាលា គឺជាប្រធាននិស្សិតក្រៅផ្លូវការ ដែលអ្នកណាៗមានបញ្ហាសុទ្ធតែនឹកឃើញដល់នាយ។

យប់នេះ ជាលើកដំបូងដែលសិស្សប្អូនផានូត្រូវការពឹងនាយ តែក៏ជាយប់ដំបូង ដែលប្រធាននិស្សិតយកជីវិតមកប្តូរដើម្បីទល់ទល់នឹងឧបសគ្គដ៏ធំធេង ក្នុងគោលដៅរក្សាឈ្មោះប្រធាននិស្សិតគ្មានគូប្រៀបរបស់ខ្លួន។ ដូចគ្នានឹងកិច្ចសន្យាជាមួយ លោកឌិត សាម៉ុន ដែលសន្យាថានឹងជួយឲ្យគេក្លាយជាប៉ូលិសពិតប្រាកដម្នាក់។ វាសនាគេពេលនេះគឺបើកភ្នែកមកវិញពិចារណាអំពីទីកន្លែងនិងអ្វីៗដែលកំពុងប្រឈមមុខ។

ការចងចាំមានលក្ខណៈយឺតៗ...

ត្រូវហើយ យើងបានស្ម័គ្រធ្វើជាវីរជន។

យើងបានស្ម័គ្រថានៅលើឡានតែម្នាក់ឯង ឲ្យប៉ូលិសនោះនាំសិស្សប្អូនរត់ ហើយខ្លួនឯងជិះឡានបកទៅរកពួកវាបម្រុងបង្វែងដានឲ្យពួកវាប្រដេញចូលក្រុងវិញ តែដឹងអីឡានវាលឿនជាងឡានរបស់ផ្ទះឧត្តមសេនីយ៍ទៅទៀត។

ឡានពួកវាមកពីបួនទិស ជាប្រភេទឡានធុន់ៗទំនើបៗ គ្រាន់តែឃើញដឹងតែស៊ូមិនរួច ប៉ុន្តែចិត្តមួយចង់ឲ្យឲ្យសិស្សប្អូននិងនាយ Hacker បង្វែងទៅឲ្យបានឆ្ងាយបន្តិចសិន ដឹងអីពួកបច្ចាមិត្តមិនបានដំអក់សូម្បីមួយគ្រលៀសភ្នែក។

ពេលរថយន្តពួកពាលវាបោលមកបំបុកក្នុងគោលដៅបញ្ឈប់នាយ ប្រហែលជាពួកនោះមិនបានគិតទេថា ក្នុងឡាននៅសល់មនុស្សតែម្នាក់ ហើយម្នាក់នោះសុខចិត្តទៅជាអ្វីក៏បានតែមិនព្រមឈប់ឡាន...

គ្រាំង!!!

គេលែងដឹងគ្រប់យ៉ាង ហើយពេលនេះភ្ញាក់មកក៏ឃើញខ្លួនឯងនៅក្នុងកន្លែងមួយដែលមហាងងឹតបែបនេះ?។

ក្រៅតែពីសំឡេងសត្វរាត្រីចរ កម្លាំងខ្យល់បោកស្លឹកឈើនិងស្រមោលព្រះចន្ទសល់តិចសែនតិច ព្រឹមៗព្រាលៗ គេមិនអាចមើលឃើញអ្វីផ្សេងឡើយ ទោះបីជាខំផ្ចង់យូរប៉ុនណាក៏ដោយ។

សណ្ឋានដីកខ្វក់ហើយសើម មិនស្រមៃដល់សភាពពិត ថាតើមានកាន់ស្លែនិងសត្វល្អូន? កខ្វក់កម្រិតណាទៅ?

ទោះយ៉ាងណា គ្មានក្លិនអ្វីទាំងអស់ សូម្បីតែលាមកពាហនៈក៏អាចផ្តល់ក្តីសង្ឃឹមថាមានអ្នកណាធ្លាប់មកក្បែរៗនេះ! តែនេះគ្មាន!.....

នាយចាប់ផ្តើមអស់សង្ឃឹមលាយឡំជាមួយចម្ងល់ថា  តើការរៀបចំកន្លែងរបៀបនេះត្រូវការពេលវេលាយូរអង្វែងប៉ុណ្ណាទៅ?  អ្នកណាខ្លះដែលអាចធ្វើការងារនេះបាន?

អារម្មណ៍ដែលចូលមកបន្ទាប់គឺការព្រួយបារម្ភដ៏ធ្ងន់ធ្ងរ។

សំណួរគឺថា បើចង់ស្វែងរកជំនួយសូម្បីតែមួយក្រេបទឹក ក៏មិនដឹងថាអាចរកបានយ៉ាងណាដើម្បីនឹងបន្តជីវិតដែរឬអត់ផង ព្រោះនៅជុំវិញនេះ ពួកមនុស្សអាក្រក់នៅតែបន្តរុករកខ្លួននៅឡើយឬពួកគេបានបោះបង់ចោល?

ព្រះអាទិត្យអើយ លោកយាងយូរៗម្ល៉េះ? លោកភ្លេចមនុស្សកន្ទើចិត្តហានក្លាម្នាក់នេះហើយពិតមែនដែរទេ?

យប់នេះមិនមែនជាករណីលេងសើចទេ។ គេប្រាប់ខ្លួនឯង... ប្រសិនឯងមានភាពវៃឆ្លាតពិតមែនឯងនឹងរស់ តែពុំនោះទេឯងនឹងលែងមានគេចងចាំទៀតហើយប្រធាននិស្សិតអើយ។

គេលង់លក់បន្តិចម្តងៗជាមួយទឹកភ្នែកសើម ជាសម្គាល់បង្ហាញពីសភាពអស់សង្ឃឹមនិងហត់ល្ហើយ។

ជារឿយៗ ឈុនរាជមានក្តីសុបិនជាច្រើនបន្តបន្ទាប់គ្នា។ ក្នុងគ្រានេះ ជួនគេសុបិនភ្នែកស្រស់អំពីរូបរាងឃាតករដែលបង្ហាញមុខជាមួយនឹងដំបង ឬអាវុធសាហាវៗនៅលើពីដៃ។ សូម្បីតែក្នុងសុបិនក៏គេដឹងថា ប្រសិនបើត្រូវពួកអស់នោះ មករកឃើញនាយពិតមែន ឈុនរាជគ្មានមធ្យោបាយអ្វីបន្តទប់ទល់នឹងពួកគេឡើយ ហើយបើទោះជាគ្មានអ្នកណាមួយមកដល់ ក៏គេនឹងដាច់ពោះ ព្រោះការចេញពីជញ្ជាំងភ្នំដ៏រឹងមាំនេះវាមិនអាចទៅរួចដែរ។

រាងកាយញាក់ចំប្រប់ព្រោះធាតុសន្សើមដ៏ត្រជាក់ បានធ្វើឱ្យនិស្សិតរូបនេះកន្ត្រាក់ដឹងខ្លួនចាកចេញពីក្តីស្រមើស្រមៃ។ ចិត្តនាយផ្តើមពេលភ្ញាក់មកវិញនៅតែឃើញខ្លួនឯងក្នុងស្ថានភាពអស់សង្ឃឹមរបៀបនេះ។

«ចាំ! អ្នកណាក៏ដោយ ក្នុងចំណោមពួកយើង! ឲ្យតែបានទាក់ទងដល់ចិត្រាឬលោកឱត សាម៉ុន ពាក្យដំបូងគេដែលត្រូវប្រាប់អ្នកទាំងពីរនោះគឺថា អ្នកចាប់យើងជាប៉ូលិស!»

ត្រូវហើយ! បំណាច់តាំងខ្លួនជាប៉ូលិស ត្រូវធ្វើជាប៉ូលិសរហូតដល់ទីបញ្ចប់ទៅ។ យ៉ាងហោចណាស់ បើមិនបានទៅផ្ទះវិញ យើងគួរតែអាចឲ្យដំណឹងណាមួយទៅដល់ដៃលោកឧត្តមសេនីយ៍ទោះបីជាដោយវិធីណាក៏ដោយ។

គេច្រត់ដៃក្រោកត្រដាបត្រដួសហើយរអិលដេកទៅវិញជាច្រើនដង ព្រោះតែដីសើមឬខ្លួនអស់កម្លាំងផងក៏មិនដឹង។ ទម្រាំអាចអង្គុយស្រួលបួលវិញ ផ្នែកខាងស្តាំក្រោមស្លាបប្រចៀវនៅឲ្យសញ្ញាឈឺចាប់ខ្លាំង។ មិនដឹងថា របួសគ្រាំនេះសំណល់មកពីកណ្តាប់ដៃអាម្នាក់ណាដែលបានដាល់គេយ៉ាងដំណំ ឬមួយក៏ការជាប់សង្កត់ក្នុងរថយន្ត? ចុះហេតុអី ខ្លួនមកនៅទីនេះម្នាក់ឯងបាន?

គ្មានអ្នកណាមួយអាចខ្វាតចេញដោយខ្លួនឯងពីក្នុងឡានដែលបោលបំបុកគ្នានោះទេ? អ្នកណាយកយើងមកចោលទីនេះ? «ឬវាគិតថាអញងាប់បាត់?»។

បទចម្រៀងដ៏ទន់ភ្លន់មួយបានលាន់មក! គេមិនជឿនឹងត្រចៀកទេ គិតពីបន្តបិទភ្នែកធ្វើមុខជូររំងាប់ភាពឈឺចាប់ ប៉ុន្តែយូរៗទៅគេស្រាប់តែបើកភ្នែកមកវិញពិចារណា។

វាមិនមែនបទភ្លេងដែលនៅជិតជាមក្នុងស្មារតី រហូតដល់បង្កើតការស្រមៃលាន់រងំទេ គិតមួយភ្លែតគេដឹងច្បាស់ថា វាគឺជាភ្លេងទូរសព្ទរបស់ខ្លួន។

«ទូរសព្ទខ្ញុំនៅក្បែរៗនេះ?»

កម្លាំងមកពីណាមិនដឹងធ្វើឲ្យប្រធាននិស្សិតអាចក្រោកបានត្រដាបត្រដួសស្ទះស្វែងរកប្រភពទូរសព្ទខ្លួន តែមិនឃើញសូម្បីតែពន្លឺមួយចម្រៀកណា។ ចុងក្រោយ វាក៏រលត់ទៅវិញបាត់ទាំងសំឡេងលែងសល់ដាន។

«ខលមកទៀតមក សូមអង្វរ!»

គេនិយាយម្នាក់ឯង កណ្ដាលបរិយាកាសសូន្យសុងអស់សង្ឃឹម។ ស្ងាត់ឈឹង… ប្រហែលមិនមែនលោកឳត សាម៉ុនទេ បើជាគាត់ម៉េចក៏ទូរសព្ទមកតែម្ដង?

អូមែនហើយ? មិនមែនគេលែងទាក់ទងមកទេ មានរឿងធំប៉ុណ្ណឹងហើយនោះ ប៉ុន្តែវាប្រហែលជាអស់ថ្មងាប់ស្ដូកហៅចូលលែងបាន? ឯងចប់ហើយអាឈុនរាជ!

គេគិតទាំងពាក់កណ្ដាលស្វាងពាក់កណ្ដាលសន្លប់។ ចិត្តរាយមាយ ទឹកចិត្តបាក់ខ្ចាត់ខ្ចាយ។

បង្វិលជំហានចុះឡើង ឡើងចុះ ទាំងមិនដឹងថា អាចវិលត្រឡប់ទៅផ្ទះវិញ ដោយដើរស្រួលបួលអ៊ីចឹងទៀតដែរអត់ ឬមួយត្រូវគេសែង?

ជើងគេប៉ះអ្វីមួយរឹង!

«ថ្ម?»

ឈានបន្ថែមសឹងជំពប់ដួលបាន!

«ជណ្ដើរ?»

ដៃនាយរាវស្ទាបសងខាង!

កាំជណ្ដើរនេះតូចចង្អៀត តែរាវមិនប៉ះជញ្ជាំងសងខាងសោះ? វាលាតសន្ធឹងធំមើលមិនឃើញឬក៏គ្មានបង្កាន់ដៃអាចដួលបាក់ថ្គាមបាន? គេរាវជើងទៅមុខទាំងចិត្តស្លុតផងឆ្ងល់ផង។

«អ្នកណានៅក្រៅ! ជួយខ្ញុំផង!»

ទោះអ្នកកាងសាលាមានភាពរឹងមាំយ៉ាងណា សំឡេងមនុស្សស្រីខ្សោយអន្លាយបែបនេះ ក្នុងកន្លែងរបៀបនេះ ពេលថ្មើរណោះ បើមិនបកក្រោយរត់ផះក្រញាំទើបចម្លែក។

គេទប់ជើង... លែងដើរតែប្រុងបកក្រោយហើយបកមិនរួច... ជាលើកដំបូងក្នុងជីវិតដែលប្រធាននិស្សិតចេះញ័រជង្គង់ដល់ថ្នាក់ដើរលែងបាន...

គេគ្មានអ្វីសម្រាប់តោងទប់រាងកាយ មានតែឱបដៃក្រពាត់ចូលគ្នាបង្ក្រាបភាពតក់ស្លុត។ ត្រចៀកផ្ចោតរកប្រភពសំឡេង ស្រាប់តែគេឮសូរដង្ហើមមនុស្សស្រីដកហាត់គឃូស...

«ខ្មោចគ្មានដង្ហើមទេ!» នាយប្រាប់ខ្លួនឯង។

«ឯងជិតស្លាប់ទៅជាខ្មោចដែរហើយ ខ្លាចស្អីទៀត?»

នៅពេលគិតដល់ពាក្យកម្លាអស់ទាំងនោះហើយ ចិត្តនាយក៏កាន់តែរឹងមាំ... សាកសពដែលស្រែកថ្ងូរឬពួកព្រលឹងដែលអណ្ដែតត្រសែតក្នុងកុនហូលីវូដជាទីចាប់ចិត្តរបស់គេ លែងអាចបន្លាចនិស្សិតទាបកន្ដុញម្នាក់នេះទៀតហើយ ព្រោះគេចាប់ផ្ដើមលាន់មាត់សួរៈ

«អ្នកណា?»

សំឡេងនាយខ្ទរមកវិញ ពេលច្រឡំស្រែកព្រោះរន្ធត់។

«ជួយផង! ជួយខ្ញុំចេញទៅ! ប៉ាខ្ញុំមានលុយច្រើនណាស់ ខ្ញុំនឹងឲ្យលុយ! ជួយខ្ញុំផង!»

ឈុនរាជស្វាងពីភាពអណ្ដែតត្រសែត។ ការបាត់ខ្លួនកូនស្រីអ្នកមានជាបន្តបន្ទាប់ បានលេចឡើងមកក្នុងអារម្មណ៍នាយហើយនាយដឹងថាអ្វីជាអ្វី។

«ពួកនោះទំនងជាចង់យកផានូមកលាក់ទីនេះ ហើយអ្វីៗបានកើតឡើងនៅកន្លែងតែមួយនេះ ជាកន្លែងដែល មនុស្សកន្ទ្បើដូចយើងនឹងបានពាក់សក្តិ!»។

គេគិតហើយរំញោចសេចក្តីក្លាហាន តាមបែបជាប្រធាននិស្សិតកាងសាលាឡើងមកវិញសាជាថ្មី។

«បងជួយបាន! ប្រាប់មក អ្នកណានិយាយ ហើយកំពុងនៅឯណា?»

ឈុនរាជនិយាយខ្សឹបៗ សួរទាំងចិត្តរាយប៉ាយ រំពៃគន់ស្វះស្វែងរកមធ្យោបាយ។

អ្នកខាងក្នុងក៏កំពុងតែមានកម្លាំងព្រឺសវិញដូចគ្នា បើធៀបសំឡេងលើកមុននិងលើកនេះ។

«ខ្ញុំឈ្មោះពិនណា! ខ្ញុំត្រូវជាប់នៅនេះបីបួនថ្ងៃហើយ! កន្លែងនេះងងឹតណាស់! បងចូលមក ត្រូវរកភ្លើងមកតាម!»

គេបន្តឈានស្ទាបៗឡើងជណ្ដើរមួយកាំហើយមួយកាំទៀត ក្នុងភាពងឿងឆ្ងល់។ កាន់តែឡើង អាកាសធាតុជុំវិញខ្លួនរឹតតែត្រជាក់ ដូចសន្សើមពេលព្រឹកតែមេឃនៅងងឹតណាស់គ្មានសញ្ញាថាព្រះទិនករងើបមកនៅឡើយទេ។

«ខ្ញុំកំណត់ទិសដៅមិនបានសោះ!»

គេរអ៊ូខ្សឹបៗ ស្រាប់តែពន្លឺមួយភ្លឺឆ្វាចនៅទិសខាងត្បូង។

**ភាគទី២៨**

វាជាពន្លឺដ៏ខ្សោយដែលចាំងមកពីចំណុចតូចបំផុតមួយហើយមានរស្មីមកបាន ដោយសារទីនេះងងឹតហួសហេតុតែប៉ុណ្ណោះ។

ទោះយ៉ាងណា គេអាចមើលឃើញថា ខ្លួនឯងកំពុងស្ថិតនៅក្នុងប្រអប់ល្អាងភ្នំមួយដែលរុំពីលើដោយស្រទាប់ជ្រលងបុព្វតាក្រាស់។

ពន្លឺសមថាជាអ្នកណាម្នាក់ដែលយាមកាមទីនេះ ហើយគេឡើងមកទាន់ពេលឈុនរាជធ្វើសកម្មភាព។ និស្សិតសសៀរទៅកាន់ទីងងឹតលាក់ខ្លួនដើម្បីសុវត្ថិភាព ឯភ្នែកទាំងសងនៅតែផ្ដោតមករកប្រភពពន្លឺ។

គ្មានអ្នកណាទាំងអស់ ប៉ុន្តែសំឡេងមួយផ្សេង លាន់មកពីប្រភពពន្លឺនោះ៖

«អ្នកណានៅខាងលើ?! ឮខ្ញុំនិយាយទេ! ខ្ញុំត្រូវការឲ្យលោកជួយ ខ្ញុំមានភ្លើង!»

សំឡេងនារីថ្មីនេះ និយាយដូចអ្នករស់នៅស្រុកគេ ហើយប្រើភាសាខ្មែរមិនរអិលប៉ុន្មានឡើយ។ អារម្មណ៍ដ៏ឆ្ងៀវឆ្ងាតរបស់បុរសនេះ បង្គាប់ឲ្យគេជះចេញនូវសំណួរបន្ទាន់៖

«ពិធីការរបស់មហាវីន? អ្នកនិយាយឈ្មោះ Rose មែនទេ?»

គូស្លងឆ្លើយទំនងជាពិចារណាដឹងហើយថា ប្រសិនបើបុរសនេះជាក្រុមដែលចាប់នាងមក គេមិន

ចាំបាច់សួរនាំអត្តសញ្ញាណនាងបញ្ជាក់នោះឡើយ។

ក្នុងភាពពេញដោយក្តីសង្ឃឹម នាងតបដោយអំណរះ

«ឆាប់មក! ដោះលែងខ្ញុំចេញពីកន្លែងនេះ!»

ជើងកាងសាលា ប្រញាប់ឈានទៅរកប្រភពពន្លឺ។

វាជះចេញពីរន្ធវែងតូចឆ្មា សមថាជាបន្ទះអ្វីមួយ ដែលបិទបាំងច្រកចុះទៅក្រោម ហើយពន្លឺគឺបានជះពីក្រោមឡើងមកលើ។